**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

# របាយការណ៍លទ្ធផល

# ស្តីពី

# ការរៀបចំទិវាជាតិអំណានលើកទី ៥




**ថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២០**

**វិ ទ្យា ស្ថា ន ប ច្ចេ ក វិ ទ្យា ក ម្ពុ ជា**

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


**សេចក្តីផ្តើម** ……………………………………………………………………១
I.**គោលបំណង** ……………………………………………………………………១
II.**យុទ្ធវិធី**……………………………………………………………………១
III.**លទ្ធផល និងសកម្មភាពនៃការប្រារព្ធទិវាជាតិអំណានលើកទី៥**……………………២
១) ការរៀបចំសន្និសីទសារព័ត៌មាន……………………………………………២
២) ការរៀបចំស្តង់តាំងពិព័រណ៌សៀវភៅ……………………………………………២
៣) សិក្ខាសាលា ស្តីពី " អំណានដំបូង " ……………………………………………៤
៤) កម្មវិធីប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ……………………………៧
៤.១-ការណែនាំបច្ចេកទេសប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ…………៧
៤.២-ការប្រារព្ធពិធីបើកការប្រឡងប្រណាំងការអាន ស្មូតកំណាព្យ និងតែងនិពន្ធ…………៩
៤.៣-ដំណើរការប្រឡងប្រណាំងការអាន ស្មូតកំណាព្យ និងតែងនិពន្ធ……………………១០
ក-ក្រុមប្រឡងប្រណាំងអានអត្ថបទ……………………………………………១០
ខ-ក្រុមប្រឡងប្រណាំងស្មូតកំណាព្យ ……………………………………………១១
គ-ក្រុមប្រឡងប្រណាំងតែងនិពន្ធ ……………………………………………១១
៤.៤-ការប្រកាសលទ្ធផលជ័យលាភី និងការបិទកម្មវិធីប្រឡងប្រណាំងអាន ស្មូត និងតែងនិពន្ធ១២
៥) កម្មវិធីប្រារព្ធទិវាជាតិអំណានលើកទី៥ ១១ មីនា ២០២០……………………………១៤
១- របាយការណ៍វឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណាន ២០១៦-២០២០…………………១៤
២-ពិធីប្រគល់ពាន និងរង្វាន់ សម្តេចតេជោហ៊ុនសែន ដល់បេក្ខជនជ័យលាភី…………………១៥
៣-ពិធីបំពាក់មេដាយជ័យលាភីកិត្តិយសជូនមន្ត្រី……………………………………………១៦
៤-ការអានអត្ថបទ និងស្មូតកំណាព្យរបស់បេក្ខជនជ័យលាភី……………………………………១៦
៥-ប្រសាសន៍សំណេះសំណាលរបស់លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន. ……………១៦
៦-បាឋកថា របស់ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអយក. …………១៧
៧-វេទិកាពិភាក្សា ស្តីពី " តួនាទីអក្សរសិល្ប៍ក្នុងសង្គម និងការតាក់តែងក្នុងសម័យឌីជីថល………១៩
IV.**សិក្ខាសាលា ស្តីពី ការផ្សព្វផ្សាយស្តង់ដាបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា**……………២១
V. **សេចក្តីសន្និដ្ឋាន**……………………………………………………………………២៤
VI. **ឧបសម្ព័ន្ធ**
***រូបភាពទី ១*** ផែនទីស្តង់តាំងពិព័រណ៌សៀវភៅ……………………………………………២៥
***រូបភាពទី ២*** បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំង " អានអត្ថបទ "……………………………២៦
***រូបភាពទី ៣*** បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំងស្មូតកំណាព្យ"……………………………២៧

**រូបភាពទី ៤** បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំង " តែងនិពន្ធ "……………………………………….…២៩
**រូបភាពទី ៥** បញ្ជីឈ្មោះបេក្ខជនជ័យលាភីប្រឡងប្រណាំង " អាន ស្ទូត តែងនិពន្ធ "………………៣០
**រូបភាពទី ៦** បញ្ជីឈ្មោះបេក្ខជនជ័យប្រឡងប្រណាំង " តាក់តែងសិក្សាកថា "…………………………៣១
**រូបភាពទី ៧** បញ្ជីឈ្មោះបេក្ខជនជ័យលាភីប្រឡងប្រណាំង " តាក់តែងសិក្សាកថា "………………..…៣២




\

**របាយការណ៍លទ្ធផល**

**ស្តីពី**

**ការរៀបចំប្រារព្ធទិវាជាតិអំណាន លើកទី៥**

**ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី " **ទិវាជាតិអំណាន** " ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ដៃគូរអភិវឌ្ឍ រៀបចំប្រារព្ធទិវាជាតិអំណានពុំអាកខានឡើយ។ លើកទី១ ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមប្រធានបទ " **បណ្តុះទំលាប់អាន ជំរុញវប្បធម៌អាន** " មានអ្នកចូលរួម ១,៨៨៣ នាក់ ដោយមានការនិទានរឿង អានរឿង និងស្មូតកំណាព្យ ជានិមិត្តរូប។ លើកទី២ ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ ក្រោមប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** " មានអ្នកចូលរួម ២,១០០ នាក់ ដោយមានកម្មវិធីប្រឡងប្រជែងអាន និងស្មូតកំណាព្យ សម្រាប់ " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** "។ លើកទី៣ ឆ្នាំ២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " មានអ្នកចូលរួម ៣,៩៦៦ នាក់ ។ លើកទី៤ ឆ្នាំ២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមប្រធានបទ " **ការអានបណ្តុះវប្បធម៌ ការសិក្សាពេញមួយជីវិត** " មានអ្នកចូលរួម ៤,០០០នាក់។ ដោយឡែក ការប្រារព្ធទិវាជាតិអំណានលើកទី៥ ឆ្នាំ២០២០ នេះ ស្ថិតក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " បានប្រព្រឹត្តទៅនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានអ្នកចូលរួមសរុប ២៥០០ នាក់។

រៀងរាល់ឆ្នាំ ការប្រារព្ធទិវាជាតិអំណាន ក្រសួងបានរៀបចំស្តង់តាំងពិព័រណ៍សៀវភៅ បង្ហាញពីស្នាដៃរបស់អ្នកនិពន្ធល្បីៗ ពិសេសសមិទ្ធិផលវិស័យអប់រំ ហើយចំនួននៃស្តង់តាំងពិព័រណ៍មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងនោះដែរ ចាប់តាំងពីការប្រារព្ធទិវាជាតិអំណានលើកទី៣ មកដល់លើកទី៥នេះ ក្រសួងបានបន្ថែមវិញ្ញាសា " ការតែងនិពន្ធ " ដើម្បីលើកកម្ពស់វប្បធម៌អាន ការស្រាវជ្រាវ និងសម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** "។

## I. គោលបំណង

ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៥ ឆ្នាំ២០២០ ក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " មានគោលបំណង បណ្តុះទម្លាប់អាន ជម្រុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ។

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានលើកទី៥ ឆ្នាំ២០២០នេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលគាប់ប្រសើរ ក្រសួងបានអនុវត្តសារាចរលេខ០២សរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពី "**ការប្រារព្ធទិវាជាតិអំណាន** " និងលិខិតលេខ ៥៧៨ សជណ.អវ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពី " **គោលការណ៍ក្នុងការផ្តល់ថវិកាសម្រាប់រង្វាន់ជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងការប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ** " រៀបចំគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំទិវាជាតិអំណានលើកទី៥ ក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និង**

**នវានុវត្តន៍** "  ដើម្បីទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ ការងារនេះ គណៈកម្មការបាន រៀបចំ ៖

ក) សេចក្តីជូនដំណឹងលេខ ៧៨ អយក.សជណ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពី ការជ្រើសរើសបេក្ខជន បេក្ខនារី ជ័យលាភី ៣រូប ជាវាគ្មិនកិត្តិយស ក្នុងការបង្ហាញពីប្រធានបទ

ខ) លិខិតលេខ ៦០២០ អយក.អកស ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពី ការអនុវត្តសេចក្តីណែនាំលេខ ៤៧ អយក.សណន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំទិវាជាតិអំណាន

**យន្តការ និងកម្មវិធីសំខាន់ៗ សម្រាប់ការប្រារព្វទិវាជាតិអំណានលើកទី៥ ឆ្នាំ២០២០**

១) ការរៀបចំសន្និសីទសារព័ត៌មាន ស្តីពី ការរៀបចំប្រារព្វទិវាជាតិអំណាន

២) ការរៀបចំស្តង់តាំងពិព័រណ៌សៀវភៅ

៣) សិក្ខាសាលា ស្តីពី " **អំណានដំបូង** "

៤) ការជ្រើសរើសបេក្ខជន បេក្ខនារី ជ័យលាភី៣រូប ជាវាគ្មិនកិត្តិយស ក្នុងការបកស្រាយប្រធានបទ

៥) កម្មវិធីប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

៦) ការប្រារព្វទិវាជាតិអំណានលើកទី៥

- សុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអយក.**
- សុន្ទរកថារបស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី**
- បាឋកថារបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអយក.**
- វេទិកាពិភាក្សា ស្តីពី " **តួនាទីអក្សរសិល្ប៍ក្នុងសង្គម និងការតែងនិពន្ធក្នុងសម័យទំនើប (ឌីជីថល)** "

៧) សិក្ខាសាលា ស្តីពី " **ស្តង់ដាបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ** " ។

## III.លទ្ធផល និងសកម្មភាពនៃការប្រារព្វពិធីទិវាជាតិអំណានលើកទី ៥

### ១) ការរៀបចំសន្និសីទសារព័ត៌មាន



ថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសន្និសីទសារព័ត៌មាន ដែលធ្វើនៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ ថ្លែងក្នុងសន្និសីទនោះ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានបង្ហាញពីការរៀបចំទិវាជាតិអំណានចាប់តាំងពីថ្ងៃទី១១ខែមីនា ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន ដោយការសហការជាមួយក្រសួងពាក់ព័ន្ធ ការចូលរួមពីថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀត បានធ្វើឱ្យមានការចូលរួមកាន់តែទូលំទូលាយ និងផុលផុស ដោយមានកម្មវិធីពិសេសៗកាន់តែច្រើនឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងគោលបំណងបំផុសឱ្យសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងមហាជន ចូលចិត្តអាន មានទម្លាប់អាន ដើម្បីបង្កើនវិជ្ជាសម្បទា ចរិយាសម្បទា បំណិនសម្បទា។

## ២) ការរៀបចំស្តង់តាំងពិព័រណ៍សៀវភៅសិក្សា



កម្មវិធីស្តង់តាំងពិព័រណ៍សៀវភៅ ត្រូវបានសម្ពោធកាត់ខ្សែរបូរដាក់ឱ្យប្រើប្រាស់ស្តង់ចំនួន១០៤មកពី៨០ក្រុមហ៊ុន ចាប់ផ្តើមពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំងវត្តមានចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ ក្រុមហ៊ុនឯកជន ក្រុមការងាររៀបចំទិវាជាតិអំណានលើកទី៥ យុវជនស្ម័គ្រចិត្ត សិស្ស និស្សិត សរុប ប្រមាណ ២០០ នាក់។




ថ្លែងក្នុងពិធីសម្ពោធស្តង់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មានប្រសាសន៍ថា ការសម្ពោធស្តង់ដាក់ឱ្យប្រើប្រាស់ក្នុងការប្រារព្ធទិវាជាតិអំណានលើកទី៥ ក្រោមប្រធានបទ"**ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " ជាព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ថ្មីជាច្រើនទៀត ដែលត្រូវបានចូលរួមយ៉ាងច្រើនកុះករ ពីដៃគូអភិវឌ្ឍ ក្រុមហ៊ុន និងគ្រឹះស្ថានបោះពុម្ពចែកផ្សាយ ដើម្បីបង្ហាញពីស្នាដៃនៃវណ្ណកម្មរបស់អ្នកនិពន្ធ។

ដើម្បីលើកកម្ពស់អំណាននៅកម្ពុជា ក្រសួងនឹងរៀបចំសិក្ខាសាលាស្តីពី " **អំណានដំបូង** " នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២០ សម្រាប់ជាមូលដ្ឋានក្នុងការបង្រៀនសិស្សថ្នាក់ទី១,២ និងដោយមានការសហការពីមូលនិធិអាស៊ី ដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្រសួងបានរៀបចំយុទ្ធនាការ ស្តីពី " **តោះយើងអានរាល់ថ្ងៃ** " រយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី៦-១៥ ខែមីនា ឆ្នាំ២០២០ នៅតាមបណ្តាខេត្តមួយចំនួន ។ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានអំពាវនាវដល់ មាតាបិតាសិស្ស អាណាព្យាបាលសិស្ស លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់ ចូលរួមចំណាយពេលអានជាមួយក្មេងពី៥ ទៅ ១០នាទីក្នុងមួយថ្ងៃ និងពង្រឹងឱ្យសិស្សមានទម្លាប់អានដោយខ្លួនឯង។

**ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានបង្ហាញពីកម្មវិធីសំខាន់ៗសម្រាប់ទិវាជាតិអំណានលើកទី៥នេះ និងបានអំពាវនាវសូមឱ្យយុវជនបង្កើន ការអានឱ្យបានច្រើនដើម្បីបណ្តុះបញ្ញា ការស្រាវជ្រាវដើម្បីលើកកំពស់ការអាន និងរក្សាអនាម័យ លាងដៃនឹងសាប៊ូ ការពារជំងឺ Covid 19 និងសុខភាពអនាម័យទាំងអស់គ្នា។




សកម្មភាពតាំងស្តង់ពិព័រណ៍សៀវភៅបានប្រព្រឹត្តិទៅរយៈពេល៣ថ្ងៃ ដោយមានសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងមហាជន ចូលរួមសរុបចំនួន ២៥០០០នាក់។ ពួកគាត់មានសកម្មភាពផ្សេងៗគ្នាដូចជា ចូលជាវ ឬអានសៀវភៅ គូររូប ថតរូប ល្បែងឆ្លើយសំណួរ និងទស្សនាទិដ្ឋភាពផ្សេងៗនៃស្តង់តាំងពិព័រណ៍។

(ជូនឧបសម្ព័ន្ធ រូបភាព ទី១ ផែនទីស្តង់ពិព័រណ៍)

## ៣) សិក្ខាសាលា ស្តីពី " អំណានដំបូង "



កម្មវិធីសិក្ខាសាលា "**អំណានដំបូង**" បានប្រព្រឹត្តទៅនាថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០២០ ចាប់ពីម៉ោង ៧: ៣០ ដល់ម៉ោង១១:៣០ នៅសាល"A" នៃវិទ្យាស្ថានពហុបច្ចេកវិទ្យាកម្ពុជា ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** និងវត្តមានចូលរួមពីប្រធាន អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្រុមការងាររៀបចំទិវាជាតិអំណាន ក្រុមយុវជនស្ម័គ្រចិត្ត គរុសិស្ស និស្សិតមកពីវិទ្យាស្ថានគរុកោសល្យ សាលាគរុកោសល្យមត្តេយ្យមជ្ឈឹម និងមាតាបិតាអាណាព្យាបាលសិស្ស សរុបប្រមាណ ៣០០ នាក់ ។

ជាកិច្ចចាប់ផ្តើម តំណាងក្រុមយុវជនស្ម័គ្រចិត្តបានបង្ហាញថា ដោយយល់ឃើញពីសារៈសំខាន់ និងមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក្រុមយុវជនស្ម័គ្រចិត្តបានសហការជាមួយអង្គការ Save the Children សាលាអប់រំកុមារតូចស៊ីជីតាកម្ពុជា សាលាបឋមសិក្សាសសរស្តម្ភខេត្តសៀមរាប រៀបចំសិក្ខាសាលា ស្តីពី " **អំណានដំបូង** " ក្នុងគោលបំណង លើកកម្ពស់អំណាន ជម្រុញការអាន និងបង្ហាញពីសារៈសំខាន់នៃអំណាន ដោយមានការធ្វើបទបង្ហាញ ស្តីពី ១)អំណានដំបូងសម្រាប់កុមារនិងគ្រួសារ ២)ការអភិវឌ្ឍខួរក្បាលកុមារនិងអំណានដំបូង ៣)វិធីបង្រៀនអំណានថ្នាក់ដំបូង និង៤)វេទិកាពិភាក្សាក្រុម។

ក្នុងឱកាសនៃពិធីបើកសិក្ខាសាលានេះ **លោកជំទាវ រដ្ឋលេខាធិការ** មានប្រសាសន៍ទៅកាន់អង្គសិក្ខាសាលាមានខ្លឹមសារសំខាន់ដូចខាងក្រោម ៖

- ក្រសួងអប់រំ យុវជន និងកីឡា គាំទ្រគំនិតរបស់ក្រុមយុវជនស្ម័គ្រចិត្ត ដែលបានរៀបចំឱ្យមានសិក្ខាសាលានេះឡើង ដោយក្រសួងយល់ឃើញថា អំណានជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ
- ធ្វើឱ្យកុមារ យុវជនកម្ពុជា មានទម្លាប់អាន សម្រាប់ជាមានមូលដ្ឋានទទួលបានការអប់រំ នាយុគសម័យសតវត្សទី២១ បានយ៉ាងល្អ
- អំណានដំបូង គណិតវិទ្យាថ្នាក់ដំបូង ជាអាទិភាពដែលក្រសួងបានយកចិត្តទុកដាក់។ ដូចនេះ ទើបក្រសួងអនុញ្ញាតឱ្យយុវជនស្ម័គ្រចិត្តអញ្ជើញវាគ្មិនទាំង៣នាក់ មកធ្វើបទបង្ហាញទាក់ទងនឹងប្រធានបទសិក្ខាសាលា ស្តីពី " អំណានដំបូង "
- ក្នុងការងារអប់រំ តួនាទីដ៏សំខាន់របស់មាតាបិតា អាណាព្យាបាលសិស្ស មានភារកិច្ចចូលរួម បង្រៀន និងអប់រំកុមារ ព្រោះពេលវេលាកុមារនៅផ្ទះ ច្រើនជាងនៅសាលារៀន។

**លោកជំទាវ រដ្ឋលេខាធិការ** បានសម្តែងការអបអរសាទរទិវា៨មីនា ដែលជាការលើកកម្ពស់សកម្មភាពនារី ដូចជាក្នុងវេទិកានេះស្រាប់ ដែលវាគ្មិនធ្វើបទបង្ហាញ សុទ្ធតែជានារីផងដែរ។

ក) បទបង្ហាញ ស្តីពី " *អំណានដំបូងសម្រាប់កុមារតូច និងគ្រួសារ* "




លោកស្រី **ខូយ រ៉ានី** ទីប្រឹក្សាកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច របស់អង្គការ Save the Children បានបង្ហាញថា ៖

- កុមារពីអាយុ ៨ខែ ដល់ ១០ខែ សកម្មភាពរៀនគឺលេង និងលេងគឺរៀន ដោយក្នុងពេលនេះ កុមារមិនទាន់អានបានទេ តែកុមារអាចស្តាប់ឮ និងស្តាប់បានតាំងពីនៅក្នុងផ្ទៃម្តាយម្ល៉េះ ដែលនេះជាមូលដ្ឋានគ្រឹះ នៃអំណាន។
- កុមារអាយុពីកើតដល់អាយុ៥ឆ្នាំ មាតាបិតា គួរជួយកូនលើបំណិន ការស្គាល់តួអក្សរ និងការស្គាល់សូរ ។ បំណិន "សូរ " ដូចជា ការហុចរបស់អ្វីមួយឱ្យកុមារ និងការប្រាប់ឈ្មោះរបស់នោះដល់កុមារ និងបំណិនស្តាប់ គឺការជួយកុមារតាមរយៈការបង្ហាញសកម្មភាព។

ខ) បទបង្ហាញ ស្តីពី " *ការអភិវឌ្ឍខួរក្បាលកុមារ និងអំណានដំបូង* "




លោកស្រី **សរ ម៉ុន្លា** នាយិកាសាលាអប់រំកុមារតូចស៊ីជីដាកម្ពុជា បានបង្ហាញមានខ្លឹមសារដូចខាងក្រោម ៖

- ទស្សនៈ និងបទពិសោធន៍ នៃការអានសៀវភៅ ឪពុកម្តាយ ត្រូវទម្លាប់ឱ្យកូនអានសៀវភៅឱ្យបានលឿន និងត្រូវចំណាយពេលឱ្យបានច្រើនសម្រាប់ការអានសៀវភៅ។ ការអានច្រើន អានលឿន ជួយឱ្យបរិមាណនៃការអានបានចំនួនច្រើន និងមានគុណភាព។
- ទស្សនៈស្តីពីការអប់រំនាពេលអនាគត ដើម្បីភាពជោគជ័យរបស់កុមារ និងយុវជន សម្រាប់ត្រៀមរៀបចំខ្លួនប្រកួតប្រជែង ក្នុងពេលអនាគត។ យើងជា មាតាបិតា អាណាព្យាបាល ត្រូវអប់រំណែនាំកូននិងសិស្សរបស់យើងឱ្យពួកគេមាន ចំណេះដឹង ការច្នៃប្រឌិត ការស្រមើស្រមៃដែលអាចធ្វើបាន ទំនាក់ទំនង ការគិតដោយឯករាជ្យ ការរៀនពីរបៀបរស់នៅដែលទាំងអស់ជាធាតុត្រៀមបម្រុងសម្រាប់ ភាពជោគជ័យរបស់ពួកគេ។
- ទស្សនៈអប់រំសម្រាប់សតវត្សទី២១ ការអានសៀវភៅត្រូវកសាងភាពវៃឆ្លាតឱ្យកូន ដោយផ្តោតសំខាន់លើ ការគិតបែបប្រាជ្ញាIQ និងការគិតបែបសរសេរ EQ។
- មុខងារខួរក្បាលក្នុងការអប់រំ ភាពជោគជ័យរបស់មនុស្សអាស្រ័យដោយការភ្ជាប់ណឺរ៉ូនក្នុងខួរក្បាល ដោយភាពភ្ញោចដែលទទួលបានពីឥន្ទ្រីយារម្មណ៍ទាំង៥ ក្នុងទំនាក់ទំនងគ្នា។
- សារៈសំខាន់នៃការអានសៀវភៅ ៖ ១)សៀវភៅធ្វើឱ្យផ្លាស់ប្តូរពិភពលោក និងជីវិត ២)មាន និងអានសៀវភៅហាក់បីដូចជា មានបណ្ឌិត ឬ អ្នកធំៗ នៅក្បែរយើង ចាំជួយយើងជានិច្ច ៣)ការធ្វើឱ្យសិស្ស កូន ចូលចិត្តអានសៀវភៅ គឺ

  ក.ឪពុកម្តាយគួរអានសៀវភៅឱ្យយល់ជាមុនសិន រួចនិទានរឿង បែបសង្ខេប ដើម្បីកូនស្តាប់បាន
  ខ.បណ្តុះទម្លាប់អាន និងរកសៀវភៅដែលក្មេងចូលចិត្ត ចាប់អារម្មណ៍ និងរក្សាសៀវភៅនោះទុកនៅផ្ទះ
  គ.ផ្តល់ពេលវេលាសម្រាប់កូនអានសៀវភៅ។

គ) បទបង្ហាញ ស្តីពី " *កម្មវិធីបង្រៀនអំណានដំបូង* "




លោកស្រី **សី ស្រីកែវ** គ្រូបង្រៀនថ្នាក់ទី១នៃសាលាបឋមសិក្សាសសរស្តម្ភ ខេត្តសៀមរាប បានបង្ហាញពីដំណើរការបណ្តុះបណ្តាលអំណានដំបូង និងការជួយឧបត្ថម្ភគាំទ្រផ្សេងៗ ទាក់ទងនឹងកម្មវិធីអំណានដំបូង ដែលមានចំណុចសំខាន់ៗដូចជា ការបណ្តុះបណ្តាលកញ្ចប់អំណានថ្នាក់ទី១ កញ្ចប់សម្ភារៈអំណាន សកម្មភាពការបង្រៀន ការតាមដានលទ្ធផលសិក្សា និងការជួយសិស្សរៀនយឺត ការជួយគាំទ្រពីអ្នកពាក់ព័ន្ធ លទ្ធផលសម្រេចបាន ចំណុចខ្លាំងនៃការអនុវត្តកម្មវិធីអំណានថ្នាក់ទី១ និងបញ្ហាប្រឈមផ្សេងៗ។

**ឃ)កម្មវិធីសំណួរ ចម្លើយ**

កម្មវិធីនេះត្រូវបានរៀបចំ និងសម្របសម្រួលដោយ មន្ត្រីបណ្ណាល័យសម្តេច ហ៊ុនសែន និងក្រុមយុវជនស្ម័គ្រចិត្ត ដោយមានសំណួរពីអ្នកចូលរួម និងផ្តល់ចម្លើយពីលោកស្រីជាអ្នកធ្វើបទបង្ហាញទាំង៣នាក់។ ខ្លឹមសារសំណួរចម្លើយមាន៖



សំណួរ) ដូចម្តេចហៅថា ការអប់រំដោយបេះដូង?

ចម្លើយ. ការអប់រំដោយបេះដូងជាការអប់រំដោយក្តីស្រឡាញ់ពិត( ការប្រើប្រាស់កាយវិការ ពាក្យសំដី ) និងក្តីស្រឡាញ់ដោយបេះដូងនេះ ជាការស្រឡាញ់ដោយគ្មានល័ក្ខខ័ណ្ឌ។

សំណួរ)តើសិស្សដែលខូចរពឹសជាងគេក្នុងថ្នាក់ត្រូវអប់រំដូចម្តេច?

ចម្លើយ. ការបង្រៀនត្រូវផ្តោតការបំរុងប្រយ័ត្នលើសិស្សនោះ និងអប់រំណែនាំគាត់ជានិច្ច ដោយជៀសវាងសិស្សនោះរំខានដល់សិស្សឯទៀត។



សំណួរ) តើក្មេងមានបញ្ហាខួរក្បាល គួរជួយបែបណា ?

ចម្លើយ.ជាការបង្រៀននៅផ្ទះដែលឪពុកម្តាយ អាណាព្យាបាល ជាអ្នកជួយគាត់

សំណួរ)តើមានវិធីសាស្ត្រអ្វីដើម្បីឱ្យកុមារចូលចិត្តអានសៀវភៅ ?

ចម្លើយ អប់រំកុមារឱ្យផ្តើមប្រើប្រាស់សៀវភៅ បង្កើតភាពទៀងទាត់ ក្នុងការប្រើប្រាស់សៀវភៅ និងបង្រៀនអាន ប្រើសៀវភៅបែបល្បែងសិក្សា។

## ៤) កម្មវិធីប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

កម្មវិធីប្រឡងប្រណាំង បានប្រព្រឹត្តទៅពីថ្ងៃទី៨-១០ ខែមីនា ឆ្នាំ២០២០ នៅសាលប្រជុំអគាររដ្ឋបាលក្រសួងអប់រំ យុវជន និងកីឡា (ចៅពញាហុក)។

**៤.១-ការណែនាំបច្ចេកទេសប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ**

សមាសភាពចូលរួមក្នុងកម្មវិធីនេះមាន ឯកឧត្តម លោកជំទាវ ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រតិភូដឹកនាំ មាតាបិតាអាណាព្យាបាលសិស្ស និងបេក្ខជនមកពី២៥ រាជធានី ខេត្ត សរុប ២០០ នាក់ ។

**ក-មតិណែនាំបច្ចេកទេសរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុផ្នែកអានអត្ថបទ**



**លោកជំទាវ ច័ន្ទ ធី រដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុផ្នែក**អាន អត្ថបទ បានណែនាំដល់បេក្ខជន ដើម្បីទទួលបានចំណាត់ថ្នាក់ជ័យលាភី មានខ្លឹមសារដូចខាងក្រោម៖

- សារៈសំខាន់នៃការអានគឺ អក្ខរាវិរុទ្ធ តួអក្សរច្បាស់លាស់ ទាក់ទាញអ្នកចង់ស្តាប់
- ការលើកដាក់សម្លេង ទឹកមុខ កែវភ្នែក កាយវិការ ដង្ហើម ឥរិយាបថ សមស្របនឹងខ្លឹមសារអត្ថបទ។

**ខ-មតិណែនាំបច្ចេកទេសរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុផ្នែកស្មូតកំណាព្យ**



**ឯកឧត្តម យ៉ាន់ ម៉ូរិន្ទ ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាអនុប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុ**ផ្នែកស្មូតកំណាព្យ បានណែនាំបេក្ខជន ដើម្បីទទួលបានចំណាត់ថ្នាក់ជ័យលាភី មានខ្លឹមសារដូចខាងក្រោម៖

- បង្ហាញពីដើមកំណើតកំណាព្យ ដូចជា ទម្រង់សិល្បៈទាំងរូបី និងអរូបី
- លំនាំបទកំណាព្យក្នុងសតវត្សទី៦ សម័យអង្គរមានបទកាកគតិ ព្រហ្មគិត ពុំនោល មនោកៃវ និងកុដុង្គលីលា និងសម័យក្រោយអង្គរមានបទពាក្យ៧,៨,៩,១០,១១ និងបច្ចុប្បន្នមានលំនាំបទលើស៦០
- ការអ៊ីនបទកំណាព្យ ដោយប្រើរលកសម្លេង ដូចជា អ៊ីនទំរលក អ៊ីនផ្កាវ័ញ្ញ៉ារ អ៊ីនផ្លូវបត់ និងអ៊ីនគ្រហឹម
- កំណាព្យសំដៅលើ ការស្មូតពិរោះ ចាប់អារម្មណ៍ និងខ្លឹមសារយកទៅអនុវត្តបាន
- ការវាយតម្លៃដាក់ពិន្ទុ ផ្អែកលើគោលការណ៍ដែលបានកំណត់រួចមកហើយ ដូចជា ស្មូតមានសម្លេងក្រអៅក្រអួន ត្រូវតាមបទ ច្បាស់លាស់តាមអក្ខរាវិរុទ្ធ និងទឹកមុខកាយវិការស្របតាមខ្លឹមសារកំណាព្យ និងឥរិយាបថ

**ឯកឧត្តម** បានស្នើសុំដល់បេក្ខជន បេក្ខនារី ស្មូតតាមលំនាំបទ និងរក្សាកេរដំណែលកំណាព្យខ្មែរ។

**គ-មតិណែនាំបច្ចេកទេសរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុផ្នែកតែងនិពន្ធ**

**ឯកឧត្តម ជ័យ ចាប ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុ** ផ្នែកតែងនិពន្ធ បានផ្តល់យោបល់ណែនាំបេក្ខជន ដើម្បីទទួលបានចំណាត់ថ្នាក់ជ័យលាភី មានខ្លឹមសារដូចខាងក្រោម៖



- ប្រសិនបើអានមិនពិរោះ គេមិនចង់ស្តាប់ ហើយអ្វីដែលយើងបានផ្សព្វផ្សាយមិនមានប្រយោជន៍
- ការតែងនិពន្ធទាមទារបទពិសោធន៍ បំណិនប្រសប់ ដែលត្រូវការនិពន្ធអត្ថបទច្រើន និងរយៈពេលយូរទើបកំណាព្យមានខ្លឹមសារល្អ ពិរោះត្រចៀក ផ្អែម និងធ្វាញ់អារម្មណ៍
- វិធីតែងកំណាព្យ មានដូចជា ការវាស់កាព្យ (បទកាកគតិ បទព្រហ្មគិត.....) ចំណាប់ជួន
- សំឡេង ត្រូវប្រើ និងញែកឱ្យច្បាស់រវាងសូរអេ និងសូរអើ
- ភាសាកាព្យ មានពាក្យតិចណាស់ដែលត្រូវប្រើ ដូចនេះត្រូវជ្រើសរើសពាក្យប្រើ សម្រិតសម្រាំង ងាយចាំ ណែងណង ស្តាប់ហើយដក់ចិត្តជិតអារម្មណ៍។
- ការសរសេរនិពន្ធត្រូវមានសេចក្តីព្រាង ជួនកាលខ្លឹមសារមួយចំនួនបានលេចឡើងភ្លាម តែក៏បាត់ទៅវិញ។

**ឃ-មតិបូកសរុបការណែនាំបច្ចេកទេស**



**លោកជំទាវ ធន់ សារ៉ុម អនុរដ្ឋលេខាធិការក្រសួង អយក. និងជាសមាជិកគណៈកម្មការគ្រប់គ្រង និងដឹកនាំទិវាជាតិអំណានលើកទី៥** បានផ្តល់យោបល់បន្ថែមថា៖

- ការប្រឡងប្រណាំងផ្នែកតែងនិពន្ធ គួរតែអនុវត្តតាមលិខិតលេខ ៦០២០ ឱ្យបានច្បាស់លាស់ ដើម្បីពង្រីកចំណេះដឹងរបស់សិស្ស ដោយខ្លឹមសារលិខិត បេក្ខជនអាចតែងជាអត្ថបទកំណាព្យ ឬការនិពន្ធរឿងខ្លី។
- ចំណងជើងនិងខ្លឹមសារអត្ថបទត្រូវតែស្របគ្នា និងស្របជាមួយនឹងប្រធានបទទិវាជាតិអំណានរបស់យើង។

**៤.២-ការប្រារព្ធពិធីបើកការប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ**



កម្មវិធីបើកការប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំងវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រតិភូដឹកនាំរាជធានី ខេត្ត មាតាបិតាអាណាព្យាបាលសិស្ស និងបេក្ខជន ២៥ រាជធានី ខេត្ត សរុប ២០០ នាក់។

**ក- របាយការណ៍វឌ្ឍនភាពនៃការប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ**

លោក **ឃិន ធី អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា** បានបង្ហាញថា យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី " **ទិវាជាតិអំណាន** " ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំទិវាជាតិអំណាន៤លើករួចមកហើយ។ លើកទី១ នៅឆ្នាំ២០១៦ ក្រោមប្រធានបទ " **បណ្តុះទំលាប់អាន ជំរុញវប្បធម៌អាន** " នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដោយមានកម្មវិធីអានអត្ថបទ និងស្មូតកំណាព្យជានិម្មិតរូប មានអ្នកចូលរួម ១,៨៨៣ នាក់។ លើកទី២ ឆ្នាំ២០១៧ ក្រោមប្រធានបទ " **អានដើម្បីភាព សុខដុមនៃជីវិត** " នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាដោយមានកម្មវិធីប្រឡងប្រជែងអានអត្ថបទ និងស្មូតកំណាព្យសម្រាប់ទទួលជ័យលាភី " ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន " មានអ្នកចូលរួម ១,៨៥០ នាក់។ លើកទី៣ ឆ្នាំ២០១៨ ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាដោយមានកម្មវិធីប្រឡងប្រជែងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធសម្រាប់ទទួលជ័យលាភី " ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន " មានអ្នកចូលរួម ៣,៩៦៦ នាក់។ លើកទី៤ ឆ្នាំ២០១៩ ក្រោមប្រធានបទ " **ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានអ្នកចូលរួម ៤,០០០ នាក់។ ការប្រារព្ធទិវាជាតិអំណានលើកទី៥ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ នេះ ស្ថិតក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " ក្រសួងអប់រំ យុវជន និងកីឡា នៅតែបន្តរៀបចំការប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងការតែងនិពន្ធ ដូចបង្ហាញជូននាពេលនេះ។

**ខ- មតិសំណេះសំណាល និងបើកកម្មវិធីប្រឡងប្រណាំង**

**ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** មានប្រសាសន៍បើកការប្រឡងប្រណាំងនេះ មានខ្លឹមសារដូចខាងក្រោម៖

- ការរៀបចំប្រឡងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធនេះ ដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងអបអរសាទរទិវាជាតិអំណានលើកទី៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ នៅវិទ្យាស្ថានពហុបច្ចេកវិទ្យាកម្ពុជា ។
- គោលបំណងនៃការប្រឡងប្រណាំង ដើម្បីអភិរក្ស និងអភិវឌ្ឍ ផ្នែកអាន ស្មូត និងតែងនិពន្ធ ឆ្លើយតបជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ក្នុងន័យនេះ ស្មារតីអភិរក្សសំដៅធ្វើឱ្យរស់ឡើងវិញ លើផ្នែកការអាន ស្មូត និងការតែងនិពន្ធ និងការអភិវឌ្ឍ គឺការរីកចម្រើនលើផ្នែកអាន ស្មូត និងតែងនិពន្ធ ។ ការខិតខំថែរក្សា និងពង្រីក គឺយើងនឹងពឹងលើកូនៗ ដែលជាក្មេងៗជំនាន់ក្រោយ។




- ការបណ្តុះជំនាញ និងបំណិន អាន ស្មូត និងតែងនិពន្ធ ដោយទាំងខ្លឹមសារ និងលំនាំបទ ត្រូវបានសម្រិតសម្រាំងស្របជាមួយនឹងបរិបទ។
- សូមកុំភ័យតក់ស្លុត និងមានទំនុកចិត្តលើគណៈកម្មការវាយតម្លៃដាក់ពិន្ទុក្នុងការផ្តល់ភាពយុត្តិធម៌ជូនដល់បេក្ខជន ព្រមទាំងរក្សាតម្លៃ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងធ្វើឱ្យបេក្ខជនអស់ចិត្តលើលទ្ធផលរបស់ខ្លួន ឆ្លុះបញ្ចាំងបង្ហាញឱ្យឃើញពី ចំណុចខ្វះខាតរបស់បេក្ខជនម្នាក់ៗ ជាពិសេសនោះ គឺ បេក្ខជនជ័យលាភី ដែលទទួលបាន ពានរង្វាន់កិត្តិយសនេះ និងក៏ភ្ជាប់ជាមួយថវិកា ដោយឡែកអ្នកមិនជាប់ជ័យលាភី កុំអស់សង្ឃឹម

ត្រូវខិតខំបន្តថែមទៀតព្រោះការខិតខំព្យាយាមនឹងបានសម្រេច។

- បេក្ខជនម្នាក់ៗ ត្រូវរៀបចំខ្លួនឱ្យបានល្អ មកប្រឡងសូមកុំភ័យនឹងបញ្ហាផ្សេងៗ ព្រោះយើងមានការពិនិត្យសុខភាពត្រឹមត្រូវ នឹងយើងត្រូវតែបន្តអនុវត្តការលាងដៃឱ្យបានជាប្រចាំ។ ការលាងដៃនេះ ជាការធានាបានសុខភាពល្អ៥០% រួចជាស្រេច ។

លទ្ធផលដែលយើងទទួលបាន គឺជាលទ្ធផលទាំងអស់គ្នា ដែលស្ថិតក្រោមម្លប់ត្រជាក់នៃសន្តិភាព។

**៤.៣-ដំណើរការប្រឡងប្រណាំងការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ**

ដំណើរការនៃការប្រឡងប្រណាំងទាំង៣ផ្នែកនេះ ត្រូវបានប្រព្រឹត្តទៅតាម ទីកន្លែងផ្សេងគ្នា មានសកម្មភាព និងលទ្ធផលដូចខាងក្រោម៖

**ក-ក្រុមប្រឡងប្រណាំងអានអត្ថបទ** បានប្រព្រឹត្តទៅនៅសាលប្រជុំនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**ក.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ



១- ល.ជ.ទ. **ច័ន្ទ ធី** រដ្ឋលេខាធិ.ក្រសួងព័ត៌មាន
២- ល. **ឃឹម សារិន** អនុប្រ.នា.អកស
៣- លស. **ម៉ៅ តាន់ណារ៉ាវី** អនុប្រ.ការិ.នា.អកស
៤- ល. **យ៉ង់ គំស៊ាន** អនុប្រ.ការិ.នា.អកស
៥- លស. **ផាន់ សុជាតា** មន្ត្រី.នា.អកស
៦- ល. **ឃិន សុធា** មន្ត្រី.នា.អកស

**ក.២** សមាសភាពបេក្ខជន

មកពី ២៥ រាជធានី ខេត្ត មាន២៥ នាក់/ស្រី ២៣ នាក់ និងកំពុងសិក្សានៅថ្នាក់៤,៥ទី៦ នៃបឋមសិក្សាចំណេះទូទៅ ( រូបភាពទី២ )

**ក.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកអានអត្ថបទ

- អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ ២ ពិន្ទុ
- សំឡេង សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ ៣ ពិន្ទុ
- មិនខុសពាក្យ មិនរំលងពាក្យ ៤ ពិន្ទុ និងឥរិយាបថសមរម្យ ១ ពិន្ទុ

**ក.៤** សកម្មភាព ក្នុងដំណើរការប្រឡងប្រណាំងផ្នែកអានអត្ថបទ បេក្ខជនម្នាក់ៗត្រូវបានឡើងអានអត្ថបទតាមអត្ថបទរៀបចំដោយគណៈកម្មការ មានចំណងជើងថា " **សេចក្ដីថ្លៃថ្នូរបស់មនុស្ស** " ( ឧបសម្ព័ន្ធ រូបភាពទី៨ ) ។

**ខ-ក្រុមប្រឡងប្រណាំងស្មូតកំណាព្យ** បានប្រព្រឹត្តទៅនៅសាលប្រជុំជាន់ទី១ អគាររដ្ឋបាលថ្មីក្រសួងអយក.។

**ខ.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ



១- ល.ជ.ទ.បណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខា.ក្រសួងអយក.
២- ឯ.ឧ **យ៉ាន់ បូរិន** ទី.ក្រសួងវប្ប. និងវិ.សិល្បៈ
៣- ឯ.ឧ **ពុំ ម៉ុនច័ន្ទរ័ត្ន** ទី.អម គ.ប.ជ.អ
៤- ល. **ខិន សុតារា** អនុប្រ.ការិ.នា.អកស.
៥- ល. **យុ លក្ខិណា** អនុប្រ.ការិ.នា.អកស.
៦- ល. **ដាំ បេន** មន្ត្រីការិ.នា.អកស.

ខ.២ សមាសភាពបេក្ខជន

មកពី ២៥ រាជធានី ខេត្ត មាន ២៣នាក់/ស្រី ២០នាក់ និងកំពុងសិក្សាថ្នាក់៧,៨,៩( ឧ. រូបភាពទី៣)។

ខ.៣ លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកស្មូតកំណាព្យ

- ស្មូតគោរពតាមលំនាំបទនៃកំណាព្យ ៤ ពិន្ទុ
- ទឹកដមពីរោះក្រអៅក្រអួន ៣ ពិន្ទុ
- សំឡេងមិនដាច់ មិនភ្លាត់ ឬភ្លាវនាំឱ្យខុសចង្វាក់ ២ ពិន្ទុ
- ទឹកមុខ កាយវិការទៅតាមបរិយាកាសនៃបទនីមួយៗ ១ ពិន្ទុ

ខ.៤ សកម្មភាព ក្នុងដំណើរការប្រឡងប្រណាំងផ្នែកស្មូតកំណាព្យ មាន ៖



- គណៈកម្មការបានណែនាំបន្ថែមពីបច្ចេកទេសនៃការស្មូត និងបង្ហាញពីដំហរយុត្តិធម៌ជូនដល់បេក្ខជន
- បេក្ខជនបានឡើងស្មូតម្តងម្នាក់ៗ តាមលំនាំបទ និងអត្ថបទដែលខ្លួនបានរៀបចំ និងតាមការអញ្ជើញរបស់អ្នកចាត់តាំងកម្មវិធី។

**គ-ក្រុមប្រឡងប្រណាំងតែងនិពន្ធ**

បានប្រព្រឹត្តទៅនៅជាន់ទី៦ នៃអគាររដ្ឋបាលថ្មីក្រសួងអប់រំ យុវជន និងកីឡា ( ចៅពញាហុក)

គ.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ



១- ឯ.ឧ **ជ័យ ចាប** ទីប្រឹក្សារាជរដ្ឋាភិបាល

២- ល.ជ.ទ **ឆន់ សារឹម** អនុរដ្ឋ.ក្រសួងអយក.

៣- ឯ.ឧ.បណ្ឌិត **ម៉ុក សារ៉ុម** អគ្គនាយករងនៃអ.គ.អ.រ

៤- ល. **យិន ធី** អនុប្រ.នា.អកស

៥- ល. **វ៉ែន សុន** សាស្ត្រាចារ្យផ្នែកនិពន្ធកំណាព្យ

៦- ល. **ព្រៃ សំបូរ** អនុប្រ.កាវិ.នា.អកស

៧- ល. **មិត្ត សំអុល** មន្ត្រីកាវិ.នា.អកស

គ.២ សមាសភាពបេក្ខជន

មកពី ២៥ រាជធានី-ខេត្ត មាន ២៥ នាក់ ក្នុងនោះស្រី ១៤ នាក់ និងកំពុងសិក្សានៅថ្នាក់មធ្យមសិក្សាទុតិយភូមិ( ឧបសម្ព័ន្ធ រូបភាពទី៤)។

គ.៣ លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកតែងនិពន្ធ

- អត្ថរូប រចនាបទ ( រង្វាស់កាព្យ ចំណាប់ចួនភាសាកាព្យ ) ៣ ពិន្ទុ
- អត្ថន័យ ( ត្រឹមត្រូវតាមប្រធានបទ ) ៣ ពិន្ទុ
- អត្ថរស ( តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌ ) ៣ ពិន្ទុ
- អក្ខរាវិរុទ្ធ ១ ពិន្ទុ

គ.៤ សកម្មភាព បេក្ខជនចូលរួមប្រឡងប្រណាំងតែងនិពន្ធទាំងអស់ បានតែងនិពន្ធតាមការជ្រើសរើស



របស់ខ្លួន ក្នុងនោះមាន ៖

- ការតែងជាពាក្យរាយ មានបេក្ខជនសរុប ០៧ នាក់ ក្នុងនោះ ស្រី០៥នាក់
- ការតែងជាពាក្យកាព្យៈ មានបេក្ខជនសរុប ១៧ នាក់ ក្នុងនោះ ស្រី០៩នាក់

**៤.៤-ការប្រកាសជ័យលាភី និងការបិទកម្មវិធីប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ**

កម្មវិធីនេះ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំងវត្តមានអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រតិភូដឹកនាំ បេក្ខជន និងអាណាព្យាបាល រាជធានី ខេត្ត សរុប ១៧៥នាក់ក្នុងនោះស្រីមាន ១០៤ នាក់។

**ក-របាយការណ៍សង្ខេប ស្តីពី ការប្រឡងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ**

**លោកជំទាវ ឧន់ សារ៉ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** បានធ្វើរបាយការណ៍ជូនអង្គពិធីមានខ្លឹមសារដូចខាងក្រោម ៖

- កម្មវិធីប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ បានចាប់ផ្តើមពីរសៀលថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២០ ដោយគណៈកម្មការវាយតម្លៃដាក់ពិន្ទុបានណែនាំបច្ចេកទេស និងណែនាំអនុវត្តជូនដល់បេក្ខជន ជាពិសេសការផ្តល់អនុសាសន៍ និងការលើកទឹកចិត្ត សម្រាប់គណៈកម្មការវាយតម្លៃដាក់ពិន្ទុ និងបេក្ខជន ពី**ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ម៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអយក.** ក្នុងពិធីបើក។
- បង្ហាញពីសមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ចំនួនបេក្ខជន និងដំណើរការប្រឡងប្រណាំងតាមផ្នែកនីមួយៗ និងទីតាមកន្លែងផ្សេងៗគ្នា
- ដំណើរការប្រឡងប្រណាំងតាក់តែងសិក្សាកថា មានបេក្ខជន១៩នាក់ក្នុងនោះស្រីមាន១នាក់។ ការប្រឡងមាន៣ប្រធានបទ គឺ ១)តួនាទីអក្សរសិល្ប៍ក្នុងសង្គម ២)តួនាទីទស្សនាវដ្តីកម្ពុសុរិយាក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរ និង៣)ការតែងនិពន្ធក្នុងយុគសម័យទំនើប ( ឌីជីថល )។ ការវាយតម្លៃ ត្រូវបានចែកចេញជាពីរផ្នែក គឺផ្នែកទី១. ការវាតម្លៃផ្នែកសំណេរ និងទី២ ការវាយតម្លៃផ្នែកឥរិយាបថ និងវោហាស័ព្ទ។

**ខ-ការស្មូតកំណាព្យ ដោយជ័យលាភី កិត្តិយស**

បេក្ខនារី **លន់ សុវណ្ណលុច** មកពីវិទ្យាល័យអប់រំពិសេស ខេត្តសៀមរាប ទទួលបានជ័យលាភីកត្តិយស បានស្មូតកំណាព្យបទ " អនិច្ចាតោថ្ម " បទពាក្យ៨ បែបពិពណ៌នា បានទទួលថវិកានិងសម្ភារៈមួយចំនួនសម្រាប់លើកទឹកចិត្ត។ ក្នុងឱកាសនោះផងដែរ ឯកឧត្តម **បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានបង្ហាញយ៉ាងពិសេសថា កំណាព្យបទនេះ ត្រូវបានតែងនិពន្ធដោយ **ឧកញ៉ា សុតន្តប្រីជាឥន្ទ** និងបានបោះពុម្ពផ្សព្វផ្សាយនៅឆ្នាំ១៩២៦។

**គ-ប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី និងការប្រកាសលទ្ធផលជ័យលាភី**

**ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** មានប្រសាសន៍ដោយមានខ្លឹមសារដូចខាងក្រោម ៖

- សូមក្មួយៗកុំភ័យតក់ស្លុត ស្លន់ស្លោរ តែត្រូវរក្សាអនាម័យ ពិសេសក្រសួងបានចេញលិខិតមួយរួចហើយ បានណែនាំឱ្យតាមគ្រប់សាលារៀន រៀបចំឱ្យមានកន្លែងលាងសម្អាតដៃ ចេះថែរក្សាសុខភាព។ យើងនឹងប្រែក្លាយបញ្ហាប្រឈមដែលកំពុងជួបប្រទះ ជំងឺCovic 19 នេះ ឱ្យក្លាយជាការរក្សាអនាម័យ ថែរក្សាសុខភាពជាប្រចាំ។
- ក្រសួងនឹងធ្វើការវាយតម្លៃដាក់ចេញវិធានការជាបន្តបន្ទាន់ពិសេសសាលារៀន នៅក្រុងសៀមរាប
- តាមរយៈស្តង់ពិពណ៍សៀវភៅ បង្ហាញថា ស្នាដៃនិពន្ធរបស់អ្នកនិពន្ធកាន់តែមានគុណភាព និងមានបរិមាណអ្នកនិពន្ធកាន់តែច្រើនឡើង ពិសេសផ្នែកប្រលោមលោក។
- ទិវាជាតិអំណាន ឆ្នាំ២០២១ យើងនឹងរៀបចំឱ្យមានការប្រឡងប្រណាំង ការតែងនិពន្ធប្រលោមលោកប្រភេទវែងៗ ដើម្បីលើកកម្ពស់ការតែងនិពន្ធ។
- ការកោតសរសើរចំពោះបេក្ខជនដែលជាប់ជ័យលាភី និងមិនជាប់ជ័យលាភីនាឆ្នាំកន្លងមក នៅតែមកចូលរួម។
- ការចែកប័ណ្ណសរសើរជូនដល់គណៈកម្មការវាយតម្លៃដាក់ពិន្ទុ បានធ្វើការងារយ៉ាងសុក្រឹត។

**ការប្រកាសលទ្ធផលជ័យលាភី**

**១.**តារាងបេក្ខជនជ័យលាភី " **អានអត្ថបទ ស្នូតកំណាព្យ និងតែងនិពន្ធ** "

| ល.រ | ឈ្មោះ | ភេទ | ឆ្នាំកំណើត | ថ្នាក់ | មកពីសាលា | ខេត្ត | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|
| ក.បេក្ខជនជ័យលាភី " **អានអត្ថបទ** " | | | | | | | |
| ១ | **នាង អេលីណា** | ស្រី | 21.06.2009 | ៦ | សាលាគ្រូយើង | រតនគិរី | **១** |
| ២ | **ឡុង សុជាវត្តី** | ស្រី | 05.05.2009 | ៦ | ប.ព្រំ ស៊ុនក្តីកណ្តាល | ព្រៃវែង | **២** |
| ៣ | **ជុស ស្រីធាន** | ស្រី | 17.03.2009 | ៦ | ប.កំពង់ស្លែង | តាកែវ | **៣** |
| ខ.បេក្ខជនជ័យលាភី " **ស្នូតកំណាព្យ** " | | | | | | | |
| ១ | **គុណ គា** | ប្រុស | 03.02.2006 | ៧ | អនុ.តេជោសែនកម្មករ | ព្រះសី.នុ | **១** |
| ២ | **ហ៊ុន ធីតា** | ស្រី | 22.09.2005 | ៩ | វិ.សុខអានថ្នល់បំបែក | តាកែវ | **២** |
| ៣ | **ខំ យុនធី** | ស្រី | 04.10.2005 | ៩ | វិ.ហ៊ុនសែនសណ្តាន់ | កំពង់ធំ | **៣** |
| គ.បេក្ខជនជ័យលាភី " **តែងនិពន្ធ** " | | | | | | | |
| ១ | **ហេង មៀនមៀន** | ស្រី | 27.04.2002 | ១២ | វិ.សម្តេចឪ | តាកែវ | **១** |
| ២ | **ងួន សុរិកា** | ស្រី | 08.11.2002 | ១១ | វិ.សម្តេចជាស៊ីមអង្គរជ័យ | កំពត | **២** |
| ៣ | **កាន ស្រីនីត** | ស្រី | 13.04.2002 | ១១ | វិ.មេសាង | ព្រៃវែង | **៣** |





២.បេក្ខជនជ័យលាភីផ្នែក " តាក់តែងសិក្សាកថា "

| ល.រ | ឈ្មោះ | ភេទ | ឆ្នាំកំណើត | មុខរបរ | អង្គភាព | ខេត្ត | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|
| ក)ប្រធានបទទី១ តួនាទីអក្សរសិល្ប៍ក្នុងសង្គម | | | | | | | |
| ១ | **យ៉ែម មករា** | ប្រុស | 08.01.89 | គ្រូបង្រៀន | វិ.អង្គរការ | ត.ក | **១** |
| ខ)ប្រធានបទទី២ តួនាទីទស្សនាវដ្ដីកម្ពុជសុរិយា | | | | | | | |
| ២ | **ឡុង ឆវង្ស** | ប្រុស | 07.10.92 | គ្រូបង្រៀន | វិ.សម្ដេច ហស សំពេង | ក.ព | **១** |
| គ)ប្រធានបទទី៣ ការតាក់តែងនិពន្ធក្នុងយុគសម័យ( ឌីជីថល) | | | | | | | |
| ៣ | **មិន ម៉ៅសំណាង** | ប្រុស | 05.05.93 | អ្នកសារព័ត៌មាន | ទូរទស្សន៍ PNN | ក.ព | **១** |

### ៤.៥-ការហាត់សមរបស់បេក្ខជនជ័យលាភី



សកម្មភាពនាពេលនេះស្ថិតក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ស៊ើ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** និងគណៈកម្មការគ្រប់គ្រងនិងដឹកនាំការរៀបចំទិវាជាតិអំណានលើកទី៥។ ការហាត់សមត្រូវបានផ្ដោតលើ សមត្ថភាពអានអត្ថបទ និងសូត្រកំណាព្យ កាយវិការមុនពេល ក្នុងពេល និងក្រោយពេលបង្ហាញសមត្ថភាពនៃវិញ្ញាសា និងការទទួលពានរង្វាន់ជ័យលាភីពី **លោកជំទាវ កិត្តិសង្គហ បណ្ឌិត ម៉ែន សំអន**។

## ៥) **កម្មវិធីប្រារព្ធទិវាជាតិអំណានលើកទី៥ ១១ មីនា ២០២០**



ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ជាថ្ងៃប្រារព្ធទិវាជាតិអំណានលើកទី៥ ក្រោមប្រធានបទ " **ការអានបណ្ដុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ សមាសភាពចូលរួមមាន ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ បុគ្គលិកអប់រំ គរុសិស្ស និស្សិត សរុបជាង ១៥០០ នាក់។

### ១. របាយការណ៍វឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណាន ២០១៦ ដល់ ២០២០

ឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានរាយការណ៍ស្ដីពី វឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណានជូន **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** និងអង្គពិធី មានខ្លឹមសារដូចខាងក្រោម ៖

- ការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ដែលបាន

អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងទិវាជាតិអំណានលើកទី៥ ឆ្នាំ២០២០ នាពេលនេះ ដើម្បីបានផ្តល់ការលើកទឹកចិត្តដល់ក្រសួងអប់រំ យុវជន និងកីឡា ពិសេសលោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និស្សិត ក្នុងការប្រឹងប្រែងបន្តទៀត ដើម្បីលើកកម្ពស់វប្បធម៌នៃការអាន ឱ្យកាន់តែទូលំទូលាយ និងដល់ប្រជាជនគ្រប់វ័យនៅទូទាំងប្រទេស។

- បង្ហាញពីការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការជ្រើសរើសយកថ្ងៃទី១១ ខែមីនា ដែលជាថ្ងៃកំណើតរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដើម្បីប្រារព្ធទិវាជាតិអំណាននេះឡើងរៀងរាល់ឆ្នាំ ក្នុងគោលបំណងរំឭកដល់វីរភាពរបសម្តេចព្រះសង្ឃរាជ ដែលបានខិតខំតស៊ូពុះពារ ការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរពីអាណានិគមនិយមបារាំង។
- បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី ការរៀបចំប្រារព្ធទិវាជាតិអំណាន ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍ រៀបចំប្រារព្ធទិវាជាតិអំណានបានចំនួន៤លើករួចមកហើយចាប់តាំងពីឆ្នាំ២០១៦ សកម្មភាពឃោសនា មានការចងបដា ការធ្វើសន្និសីទសារព័ត៌មាន និងការប្រកួតប្រជែងអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ។ ដោយឡែកឆ្នាំ២០២០នេះ ក្រសួងបានរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៥ ស្ថិតក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** "។ ដូចឆ្នាំកន្លងមកដែរ ក្រសួងបានបង្កើតឱ្យមានការប្រកួតប្រជែងការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីទទួល "**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**"។ ក្រៅពីនេះ ក្រសួងក៏បានរៀបចំជាស្តង់តាំងពិព័រណ៍សៀវភៅចំនួន១០៤ ស្តង់ មកពី៨០ស្ថាប័ន មានការរៀបសិក្ខាសាលាអំណានដំបូងព្រមទាំងបានរៀបចំយុទ្ធនាការ "តោះអានទាំងអស់គ្នា "។ បន្ថែមលើសពីនេះ ក៏នឹងមានការធ្វើបាឋកថា ពី " អក្សរសិល្ប៍ និងភាសាខ្មែរ សម័យមុនអង្គរ និងសម័យអង្គរតាមរយៈសិលាចារឹក " ដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី និងវេទិកាពិភាក្សា ស្តីពី " តួនាទីអក្សរសិល្ប៍ក្នុងសង្គម និងការតាក់តែងនិពន្ធក្នុងសម័យឌីជីថល។

## ២. ពិធីប្រគល់ពានរង្វាន់ " សម្តេចតេជោ ហ៊ុន សែន " និងប្រកាសនីយបត្រកិត្តិយស



ក្នុងពិធីនេះ បេក្ខជនជ័យលាភីលេខ១,២ និងលេខ៣ ផ្នែកអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ និងលេខ១ ការតាក់តែងសិក្សាកថាទាំង៣ផ្នែក បានទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " និង" **ប្រកាសនីយបត្រកិត្តិយស** " **ពីលោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**។





**៣. ពិធីបំពាក់មេដាយកិត្តិយស**

ក្នុងពិធីនេះ **លោកបណ្ឌិត អាំង ជូលាន** និងលោកស្រីបណ្ឌិត **ឆោម គន្ធា** បានទទួលគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ពី **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** ផងដែរ។

**៤. ការអានអត្ថបទ និងសូត្រកំណាព្យ ដោយបេក្ខជនជ័យលាភី លេខ១**

ក. យុវសិស្ស **នាង អេលីណា** មកពីសាលាបឋមសិក្សាគ្រូយើង ខេត្តរតនគិរី ជាជ័យលាភីលេខ១ ផ្នែកអានអត្ថបទ បានអានអត្ថបទមានចំណងជើងថា " សេចក្តីថ្លៃថ្នូររបស់មនុស្ស " ដកស្រង់ពីសៀវភៅសិក្សាភាសាខ្មែរថ្នាក់ទី៦។

ខ. យុវសិស្ស **គុណ គា** មកពីអនុវិទ្យាល័យតេជោសែនកម្មករ ខេត្តព្រះសីហនុ ជាជ័យលាភីលេខ១ ផ្នែកសូត្រកំណាព្យ បានសូត្រកំណាព្យ ក្រោមចំណងជើងថា " **និស្ស័យស្នេហ៍អំណាន** " ដែលជាស្នាដៃនិពន្ធរបស់យុវសិស្ស **ហេង មៀនមៀន** មកពីវិទ្យាល័យសម្តេចឪ ខេត្តតាកែវ ជាជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ ។

**៥. ប្រសាសន៍សំណេះសំណាលរបស់ លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**




បទសំណេះសំណាលរបស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មានខ្លឹមសារដូចខាងក្រោម ៖

- ទឹកចិត្តរីករាយដែលបានចូលរួមក្នុងពិធីទិវាជាតិអំណានលើកទី៥ ដ៏មានអត្ថន័យនេះ និងការបង្ហាញពីបុព្វហេតុដែលរាជរដ្ឋាភិបាលបានកំណត់យកថ្ងៃ១១ ខែមីនា ជាការប្រារព្ធទិវាជាតិអំណាន ក្នុងបំណងគោរពដឹងគុណដល់ **សម្តេច ព្រះសង្ឃរាជ ជួន ណាត** ដែលព្រះអង្គខិតខំតស៊ូ ចងក្រង ថែរក្សា អក្សរសាស្ត្រខ្មែរ ឱ្យបានគង់វង្សមកទល់ពេលនេះ។
- កោតសរសើរដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានសហការជាមួយក្រសួងពាក់ព័ន្ធ រួមគ្នាប្រារព្ធទិវាជាតិអំណានលើកទី៥ មានប្រធានបទ ស្តីពី " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " ដែលមានខ្លឹមសារជាទីទាក់ទាញ កាន់តែល្អ សំដៅលើកតម្កើងអក្សរសាស្ត្រ និងអរិយធម៌ខ្មែរ ប្រកបដោយការទទួលខុសត្រូវ។ ពិសេសប្រធានបទនៃការប្រារព្ធទិវាជាតិនេះ ស្របពេលរីកចម្រើនឆាប់រហ័សនៃទូរស័ព្ទដៃ និងសម័យកាល Digitalទំនើប និងដោយឡែកនិន្នាការបច្ចុប្បន្ន សេដ្ឋកិច្ចសកលលោកកំពុងតែរីកចម្រើន ដែលកម្ពុជាត្រូវការប្រកួតប្រជែង ពិសេសសេដ្ឋកិច្ចក្នុងតំបន់ដែលយើងត្រូវការធនធានមនុស្សជាចាំបាច់ ទាំងផ្នែកចំណេះដឹង ការស្រាវជ្រាវ និងនវានុវត្តន៍ សម្រាប់ឆ្លើយតបនឹងតម្រូវការទាំងអស់នោះ។
- តើហេតុអ្វីបានជាយើងត្រូវអានសៀវភៅ ព្រោះសៀវភៅជាឃ្លាំងផ្ទុកនូវព័ត៌មាន និងការអានមានសារៈសំខាន់ដូចជា អានបានយល់ពីសភាពការ រកការងារធ្វើបានល្អ ជួយបណ្តុះការអភិវឌ្ឍចិត្ត បង្កើនភាពរស់រវើករបស់ខួរក្បាល ពិសេសនាំនូវបេកគំហើញថ្មីៗ
- សៀវភៅ ឯកសារ ទស្សនាវដ្តី ជាឧបករណ៍ស្រាវជ្រាវសំបូរបែបដែលបង្កប់អត្ថន័យព័ត៌មានថ្មីៗ ដូចសុភាសិតពោលថា " ស្លាបប៉ាកកា មានឥទ្ធិពលមុតស្រួច និងខ្លាំងជាងដាវទៅទៀត " ព្រោះការនិពន្ធទស្សនាវដ្តី

នយោបាយ ផ្សេងៗ ជាគំនិតដែលតាក់តែងដោយស្លាបប៉ាកា ធ្វើឱ្យមានការផ្លាស់ប្តូររបបនយោបាយ និងដោគវិាសនាសង្គម ។

- ពេញចិត្តនឹងកម្មវិធីបាឋកថា ស្តីពី " **អក្សរសិល្ប៍ និងភាសាខ្មែរ សម័យមុនអង្គរ និងសម័យអង្គរតាមរយៈសិលាចារឹក** " និង ខ្លឹមសារកិច្ចពិភាក្សា ស្តីពី " **តួនាទីអក្សរសិល្ប៍ក្នុងសង្គម និងការតែងនិពន្ធក្នុងសម័យទំនើប ( ឌីជីថល )** "
- បច្ចុប្បន្នយុវជនយើងកំពុងជក់ចិត្តជាមួយនឹង ការស្តាប់ចម្រៀង និងទិញទំនិញតាម On line ជាដើម ភ្លេចការអានសៀវភៅ។ ដូចនេះ ការបង្កើនអំណាន ចាំបាច់ត្រូវមានសៀវភៅ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋងាកមករកការអាន លើកកម្ពស់តួនាទីអាន និងពង្រីកការលើកទឹកចិត្តអ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយ។
- ស្របតាមបរិបទរីកចម្រើននេះ រាជរដ្ឋាភិបាល បានបង្កើតឱ្យមានបណ្ណាល័យ និងជម្រុញការបោះពុម្ពសៀវភៅសម្រាប់ការសិក្សាស្រាវជ្រាវ។

## សេចក្តីការអំពាវនាវ របស់លោកជំទាវ កិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី

សូមក្រសួងអប់រំ យុវជន និងកីឡា រៀបចំប្រារព្ធទិវាជាតិអំណានដោយបង្កើតកម្មវិធីឱ្យកាន់តែសំបូរបែបប្រកបដោយគុណភាព ដូចជា កម្មវិធីអំណានដំបូង កម្មវិធីតោះយើងអានទាំងអស់គ្នា កម្មវិធីបង្រៀនអក្ខរកម្ម និងបង្កើតមាតិកាអប់រំ តាមDigital បន្ថែមទៀត ដើម្បីផ្សព្វផ្សាយចែករំលែក និងបានអំពាវនាវ ៖

១. ប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិក សិស្ស និស្សិត ត្រូវចូលរួមអាន និងសិក្សាស្រាវជ្រាវ តាមគ្រប់លទ្ធភាព

២. ក្រសួងអប់រំ យុវជន និងកីឡាត្រូវបង្កើតកម្មវិធីនានាដែលជាមូលដ្ឋានគ្រឹះសម្រាប់សិស្សានុសិស្ស និងយុវជនអាចមានលទ្ធភាពបន្តការសិក្សា

៣.គ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ត្រូវខិតខំឱ្យអស់លទ្ធភាព បង្កើតបណ្ណាល័យ ឬជ្រុងអំណាន

៤. ក្រសួង ស្ថាប័ននានាត្រូវរៀបចំឱ្យមានបណ្ណាល័យ ឬមជ្ឈមណ្ឌលរក្សាឯកសារ ទោះជាបណ្ណាល័យធម្មតា ឬបណ្ណាល័យឌីជីថលក្តី

៥. ចៅៗ ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្រុមយុវជនទាំងអស់ ត្រូវចូលរួមឱ្យកាន់តែសកម្មក្នុងអំណាន

៦. មាតាបិតា អ្នកអាណាព្យាបាលគួរលៃលកចំណាយក្នុងគ្រួសារ សម្រាប់ទិញសៀវភៅអាន សម្ភារៈសិក្សាទុកជាអំណោយដល់កូនៗជាទីស្រឡាញ់សម្រាប់សិក្សា។

**លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** បានពេញចិត្ត និងកោតសរសើរ ដល់ខ្លឹមសារកំណាព្យមានចំណងជើងថា " **និស្ស័យស្នេហ៍អំណាន** " ដែលត្រូវបានស្មូត អមដោយទឹកដមសម្លេងរបស់ យុវសិស្ស **គុណ គា** បេក្ខជនជ័យលាភីស្មូតកំណាព្យ និងសូមឱ្យយកកំណាព្យបទនេះ ផ្សព្វផ្សាយតាមទូរទស្សន៍ និងប្រព័ន្ធផ្សេងៗឱ្យបានច្រើន។

## ៦. បាឋកថា ស្តីពី " ភាសា និងអក្សរសិល្ប៍កម្ពុជា សម័យមុនអង្គរ និងសម័យអង្គរ តាមរយៈសិលាចារឹក "

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានធ្វើបាឋកថា ស្តីពី " **ភាសា និងអក្សរសិល្ប៍ខ្មែរ សម័យមុនអង្គរ និងសម័យអង្គរ តាមរយៈសិលាចារឹក** " មានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

### ក. អក្សរសិល្ប៍កម្ពុជាសម័យមុនអង្គរ



. អាណាចក្រខ្មែរដំបូង ចំណុចនេះបានបង្ហាញពី អាណាចក្រភ្នំ ឬហ្វូណន, ទស្សនៈរបស់អ្នកប្រាជ្ញផ្សេងៗទៀត, អង្គរបុរី ឬនវរនគរ, សិលាចារឹកវ៉ូកាញ់, អង្គរបុរីជាជង្រុកវប្បធម៌បុរេអង្គរ,លិង្គបុរៈនៅសតវត្សទី៥និងទី៦

. កំណើតភាសាសរសេរខ្មែរចាស់នៅសតវត្សទី៦ បានបង្ហាញពី សិលាចារឹកបុរេអង្គរ, ការបង្កើតអក្ខរក្រមខ្មែរចាស់, សិលាចារឹកមហាសករាជទី៥, សិលាចារឹកមហាសករាជទី៦, មជ្ឈមណ្ឌលវប្បធម៌ខ្មែរដំបូង(សតវត្សទី៦ និងដើមទី៧ នៃគ្រឹស្តសករាជ),ព្រះបាទភវវម៌្ម ទី១(៥៥០-៦០០), ស្ថាបត្យកម្មនៃប្រាសាទខ្មែរបុរេអង្គរ, ស្ទឹងត្រែងនៅសតវត្សទី៦,សិលាចារឹកសតវត្សទី៧, មហេន្ទ្រវម៌្ម-ចិត្រសេន(៦០០-៦១៦), ស្ទឹងត្រែងនៅសតវត្សទី៧, អង្គរបុរីនៅសតវត្សទី៧។

. ឥ្ស៊ានបុរៈ មានខ្លឹមសារដូចជា ព្រះបាទឥ្សានវម៌្មទី១(៦១៦-៦៣៥), ព្រះបាទភវវម៌្មទី២(៦៣៥-៦៥៧), ព្រះបាទជ័យវម៌្មទី១(៦៥៧-៦៨១),បញ្ហាប្រវត្តិសាស្ត្រកម្ពុជានៅសតវត្សទី៨, សម្ភុបុរៈ(ក្រចេះ)។

### ខ.អក្សរសិល្ប៍កម្ពុជាសម័យអង្គរ

ខ្លឹមសារបានបង្ហាញពី ព្រះបាទជ័យវម៌្មទី២(៨០២-៨៥០)និងព្រះបាទជ័យវម៌្មទី៣(៨៥៤-៨៧៧), ព្រះបាទឥន្ទ្រវម៌្មទី១(៨៧៧-៨៨៩), ព្រះបាទយសោវម៌្មទី១(៨៨៩-ប្រហែល៩១៥),ព្រះបាទហស៌វម៌្មទី១-ឥ្សានវម៌្មទី២(៩១៥-៩២៨), ព្រះបាទជ័យវម៌្មទី៤(៩២១-៩៤១), ព្រះបាទរាជេន្ទ្រវម៌្ម(៩៤៤-៩៦៨), ), ព្រះបាទជ័យវម៌្មទី៥(៩៦៨-១០០០), ព្រះបាទសូរ្យវម៌្មទី១(១០១១-១០៤៩), ប្រាសាទនិងសិលាចារឹកឯកភ្នំ ( ១០៥០-១០៦៦), ព្រះបាទឧទ័យាទិត្យវម៌្មទី៥(១០៥០-១០៦៦), ព្រះបាទហស៌វម៌្មទី៣(១០៦៦-១០៨០), ព្រះបាទជ័យវម៌្មទី៦នៃរាជវង្សមហីធរបុរ(១០៨០-១១៦០), ព្រះបាទធរណីន្ទ្រវម៌្មទី១ (១១០៧-១១១២), ព្រះបាទធរណីន្ទ្រវម៌្មទី២ (១១១៣-១១៥០), ព្រះបាទធរណីន្ទ្រវម៌្មទី២ យសោវម៌្ម ទី២(១១៥២-១១៦៥), ព្រះបាទត្រិភូវនាទិត្យវម៌្ម (១១៦៥-១១៧៧), ព្រះបាទជ័យវម៌្មទី៧(១០៨១-១២១៨), ព្រះបាទឥន្ទ្រវម៌្មទី២និងព្រះបាទជ័យវម៌្មទី៨(១២១៨-១២៩៥), សិលាចារឹកគឺជានិមិត្តរូបនៃភាពរុងរឿង, ការធ្លាក់ចុះនៃអង្គរ។

### គ.ការវិវត្តនៃភាសាខ្មែរចាស់

ខ្លឹមសារមាន ការវិវដ្តនៃអក្ខរក្រមភាសាខ្មែរចាស់, វាក្យស័ព្ទនៃភាសាខ្មែរចាស់, វាក្យសម្ព័ន្ធក្នុងភាសាខ្មែរចាស់, ការវិវដ្តវាក្យស័ព្ទពីខ្មែរចាស់ទៅខ្មែរទំនើប, មូលដ្ឋានគ្រឹះនៃភាសាខ្មែរចាស់, នាមក្នុងភាសាខ្មែរចាស់។

ក្នុងឱកាសនៃការធ្វើបទបង្ហាញនេះ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់៖

. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្ទឹងត្រែង ក្រចេះ កំពង់ចាម តាកែវ និងបាត់ដំបង ដែលបានជួយសម្របសម្រួលជូនឯកឧត្តម ក្នុងការចុះទស្សនកិច្ចសិក្សា ថតរូប និងការស្រាវជ្រាវផ្សេងៗ។

. លោកស្រីបណ្ឌិត **ឆោម គន្ធា** ដែលបានបង្រៀនភាសាសំស្ក្រឹត ណែនាំឱ្យចេះអាន និងផ្តល់អនុសាសន៍ ដល់ឯកឧត្តម ក្នុងការសិក្សាស្រាវជ្រាវ។

. លោកបណ្ឌិត **អាំង ជូលាន** សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលបានជួយនិងផ្តល់ឯកសារ។

ឆ្លងតាមការស្រាវជ្រាវ និងសិក្សាលើ " ប្រវត្តិសាស្ត្រអក្សរសាស្ត្រមុនសម័យអង្គរ សម័យអង្គរ និងក្រោយអង្គរ " ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី បានបន្ថែមថា ៖

**១.** វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យាគួរតែគិតលើ ចំណុច C 3 គឺ

C1= ខ្លឹមសារមេរៀនគួរឱ្យទុកចិត្តបាន ដោយមានភស្តុតាងគួជាទីទុកចិត្ត

C2= សង្គតិភាព គឺការស្រាវជ្រាវរកឃើញ ឬមានលក្ខណៈដូចគ្នា ឬ ស្រដៀងគ្នា

C3= មានការសហការត្រូវគ្នា ស៊ីសង្វាក់គ្នា ឬទេ

**២.** កម្មវិធីសិក្សាល្អ គួរតែមាន ១)ខ្លឹមសារឯកសារមានប្រភព ២)មានវិធីសាស្ត្របង្រៀន ៣)បង្រៀនសិស្សទទួលបានបំណិន។

**៧. វេទិកាពិភាក្សា ស្តីពី " តួនាទីអក្សរសិល្ប៍ក្នុងសង្គម និងការតាក់តែងនិពន្ធក្នុងសម័យទំនើប ( ឌីជីថល ) "**



ក្នុងវេទិកាពិភាក្សានេះ ត្រូវបានសម្របសម្រួលពី **លោកជំទាវ បណ្ឌិត ឃួន ទិច្ឆិកា** អគ្គនាយករងនៃ **អគ្គនាយដ្ឋានអប់រំ** និងស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋ**មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំងវាគ្មិនជាច្រើនរូបទៀត។ កិច្ចពិភាក្សា មានខ្លឹមសារដូចខាងក្រោម៖

**ក.** លោក **ស សុខនី** និពន្ធនាយកទស្សនាវដ្តីកម្ពុជសុរិយា និងជាប្រធានពុទ្ធសាសនបណ្ឌិត្យមានប្រសាសន៍បង្ហាញពី ៖

1. ដំណើរវិវដ្តរបស់ទស្សនាវដ្តីកម្ពុជសុរិយា និងរាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ

. រាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យកើតឡើងនៅឆ្នាំ១៩២៥ និងឆ្នាំ១៩២៦ ទស្សនាវដ្តីកម្ពុជសុរិយាត្រូវបានបង្កើតឡើង ( មានរយៈពេល៩០ ឆ្នាំ )

. ទស្សនាវដ្តីកម្ពុជសុរិយា ជាទស្សនាវដ្តីដំបូងគេទី១ ដែលបានបោះពុម្ពភាសាខ្មែរ

. ទស្សនាវដ្តីកម្ពុជសុរិយា មានតួនាទី ជាឃ្លាំងផ្សព្វផ្សាយទ្រឹស្តីពុទ្ធសាសនា ជាឃ្លាំងអក្សរសាស្ត្រ និងការផ្សព្វផ្សាយព្រឹត្តិការណ៍សាសនា។

2. ទាក់ទងនឹងប្រធានបទពិភាក្សា

រាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ បានរៀបចំការបោះពុម្ពឡើងវិញឯកសារចាស់ៗយូរឆ្នាំ ខ្លះជាវចនានុក្រមខ្មែរ ខ្លះជារឿងប្រលោមលោក និងខ្លះទៀតជាប្រជុំរឿងព្រេង មានដូចជា រឿងរាមកេរ , មហាទេពសាមកុក , ប្រជុំរឿងព្រេងខ្មែរ , ទសជាតិ , ល្បែងដកចេញពីសាស្ត្រាស្លឹករឹត , ទឹកទន្លេសាប ជាដើម ដែលរឿងទាំងអស់នេះ ត្រូវបានរៀបចំឡើងវិញ ១៩៣២(មហាទេព ) រហូតជា បណ្តើរៗ ដល់ឆ្នាំ២០១៥ ( ប្រជុំរឿងព្រេងខ្មែរ ) ដោយមានទម្រង់ច្រើនបែប ដូចជា ខ្លះបានថតជាឌីស ខ្លះទៀតស្កេនឡើងវិញ និងខ្លះបកប្រែពីភាសាបរទេស មកជាភាសាខ្មែរ។

**ខ. ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

មានប្រសាសន៍ថា ទស្សនាវដ្ដីកម្ពុជសុរិយា និងរាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានតួនាទីសំខាន់ពីរគឺ ការកសាងអត្តសញ្ញាណជាតិ និងការលើកកម្ពស់ការសិក្សាអក្សរសិល្ប៍ខ្មែរ ដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានស្រាវជ្រាវរកឃើញសៀវភៅ និងខ្លឹមសារមួយចំនួនតាមរយៈគេហទំព័រទស្សនាវដ្ដីកម្ពុជសុរិយា និងរាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានដូចជា ៖

- ឆ្នាំ១៨៤១ ព្រះបាទអង្គដួង បានឡើងសោយរាជ្យ បើកឱ្យមានសាលាវត្ត និងពេលនោះភាសាខ្មែរមានមូលដ្ឋាន នៅក្នុងសាលាបាលី។
- ឆ្នាំ១៩០៤ ព្រះបាទស៊ីសុវត្ថិ បានឡើងសោយរាជ្យ និងនៅឆ្នាំ១៩០៩ ព្រះអង្គបានរៀបចំឱ្យសាលាបាលីអង្គរដំណើរការឡើងវិញ និងនៅដើមសតវត្សឌី២០ ជាការជួសជុលអង្គរ
- ឆ្នាំ១៩២៦ ទស្សនាវដ្ដីកម្ពុជសុរិយា ត្រូវបានបង្កើតឡើង
- ក្រុមជំនុំទំនៀមទំលាប់ខ្មែរ បានរៀបចំបោះពុម្ព ពីប្រវត្តិភូមិ ឃុំ ស្រុក ខេត្ត ភ្នំ និងរឿងនិទានផ្សេងៗ តាមខេត្ត នីមួយៗ
- នៅឆ្នាំ១៩៧៥ ក្រុមជំនុំ ខ្មែរ បានរៀបចំ កម្មវិធីសិក្សាដោយតម្រូវឱ្យ សិស្សនៅតាមវិទ្យាល័យត្រូវតែអានរឿងព្រេងនិទាន
- ការប្រើប្រាស់ភាសាខ្មែរនៅមុនឆ្នាំ១៩៦៧ ជាការរៀនបែបភាសាខ្មែរចាស់ និងក្រោយឆ្នាំ១៩៦៧ ការរៀនជាភាសាខេមរយានកម្ម
- អ្នកនិពន្ធ លី ហាប់ អាន ជាអ្នកបោះពុម្ពប្រវត្តិសាស្ត្រអក្សរសាស្ត្រក្រោយសម័យអង្គរ

ប្រសាសន៍ជារួមបញ្ជាក់ថា រាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ និងទស្សនាវដ្ដីកម្ពុជសុរិយា ជាមូលដ្ឋានមួយ ធ្វើឱ្យរស់ឡើងវិញនូវវប្បធម៌ខ្មែរ " ។ កន្លងមក វប្បធម៌ខ្មែរបានធ្លាក់ដល់សូន្យ ដោយសារសង្គ្រាមក្នុងស្រុក ។ ដូចនេះ យើងទាំងអស់គ្នា ត្រូវខំប្រឹង លើកកម្ពស់អាន ស្រាវជ្រាវ និងសិក្សាពីប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងភាសាខ្មែរ ។

**គ.លោក ឡុង ឆវង្ស គ្រូបង្រៀននៅវិទ្យាល័យ** សម្ដេចអគ្គមហាសេនាបតីតេជោសំរោង រាជធានីភ្នំពេញ

មានប្រសាសន៍ថា ការបោះពុម្ពរបស់រាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យពីឆ្នាំ១៩២៦ ដល់ ១៩៧៣ ច្រើនប្រមូលផ្តុំចងក្រងឯកសារចេញពីសាស្ត្រស្លឹករឹត និងបច្ចុប្បន្នឯកសារមួយចំនួនភាគច្រើន ត្រូវបានបញ្ចូលមកជាលក្ខណៈឌីជីថល និងបោះពុម្ពជាសៀវភៅឡើងវិញ។

**ឃ.លោក យ៉េម មករា គ្រូបង្រៀនវិទ្យាល័យ** អង្គរការ ខេត្តតាកែវ

លោកសាស្ត្រាចារ្យ បានបង្ហាញថា អក្សរសិល្ប៍មានតួនាទីផ្តល់នូវ ៖

- វិជ្ជាសម្បទា សិស្សទទួលបាននូវពុទ្ធិ
- បំណិនសម្បទា ពង្រឹងឱ្យអ្នកអាន អ្នកសិក្សា ចេះយោគយល់គ្នា
- ចរិយាសម្បទា ធ្វើឱ្យអ្នកអានមានសីលធម៌ល្អ
- តម្លៃសម្បទា កសាងបានស្មារតីសាមគ្គីភាព មានការសហការគ្នា ចេះរស់ជាមួយគ្នា

**ង.លោក មិន ម៉ៅសំណាង អ្នកសារព័ត៌មាន** នៃស្ថានីយទូរទស្សន៍ PNN

លោកមានប្រសាសន៍បញ្ជាក់ថា ផ្នែកអំណានងាយស្រួល ដោយបច្ចុប្បន្នឯកសារបោះពុម្ព មានភាពសំបូរបែបរួមទាំងគេហទំព័រ ដោយអ្នកនិពន្ធ អ្នកប្រើ អ្នកទិញ ទាំងអស់គ្នាសុទ្ធតែស្ថិតក្នុងសម័យឌីជីថល។

ពាក់ព័ន្ធនឹងខ្លឹមសារពិភាក្សាដែលវាគ្មិនបានបង្ហាញខាងលើ អ្នកចូលរួមមានសំណួរ និងត្រូវបានស្រាយបំភ្លឺ មាន

ខ្លឹមសារដូចខាងក្រោម ៖

. លោក ស្រង់ វីរៈ មកពីវិទ្យាល័យ ហ៊ុន សែន ក្រែក ខេត្តត្បូងឃ្មុំ

សំណួរ ៖ តើការនិពន្ធបែប Digital នាំឱ្យបាត់សម្រស់ដែរ ឬ ទេ ?

ចម្លើយ ៖ . សម្រស់របស់អត្ថបទនិពន្ធ គឺអាស្រ័យលើការត្រូវរ៉ាយរ៉ាប់ឱ្យចំតាមស្ថានភាពជាក់ស្តែង។

. អត្ថបទតែងនិពន្ធ ត្រូវធ្វើឱ្យមានភាពជាក់ស្តែង ស្របតាមយុគសម័យឌីជីថល។

. អ្នកសារព័ត៌មាន

សំណួរ តើត្រូវធ្វើដូចម្តេច ដើម្បីការពារអត្ថបទដែលបានបោះពុម្ពផ្សាយមិនប៉ះពាល់ ដល់សាធារណៈជន ?

ចម្លើយ ប្រសិនបើប្រព័ន្ធព័ត៌មានសរសេរមិនពិតខុស បំពុលបរិយាកាស នោះនឹងប្រឈមជាមួយផ្លូវច្បាប់ ។

. លោក សាំង ពិសី គរុសិស្សមកពីសាលាគរុកោសល្យមត្តេយ្យមជ្ឈឹម

សំណួរទី១ ការនិពន្ធនៅក្នុងទសវត្សរ៍សម័យ៦០ និងការនិពន្ធក្នុងសម័យDigital ខុសគ្នា ដូចម្តេច?

ចម្លើយ ទសវត្ស ឆ្នាំ៦០ ជាសម័យឯករាជ ខ្លឹមសាររឿងបង្ហាញពីការតស៊ូ ទាក់ទងនឹងការអប់រំជីវិតឱ្យចេះតស៊ូ។ អត្ថបទតែងនិពន្ធដែលល្អ គឺជាអត្ថបទដែលអាចអាននិងប្រើប្រាស់បានគ្រប់សម័យកាល ។

សំណួរទី២ តើយើងត្រូវធ្វើដូចម្តេច ដើម្បីឱ្យការនិពន្ធក្នុងសម័យ Digital ស្ថិតស្ថេរ ?

ចម្លើយ ការនិពន្ធត្រូវផ្តោតលើ ៖

- មានទម្រង់ច្បាស់លាស់ ជាសារព័ត៌មាន ជាប្រលោមលោក ជាអត្ថបទ
- ខ្លឹមសារ ចង់ដឹកនាំអ្នកអានយល់ពីអ្វី ដឹកនាំទៅណា
- សីលធម៌ សំដី ភាសានិយាយ ( ពីចាស់ទៅក្មេង ឬ ពីក្មេងទៅចាស់ )

ជារួម " **ការសរសេរ និងការតែងនិពន្ធ ពិតជាបានថែរក្សាព្រលឹងជាតិ និងវប្បធម៌ខ្មែរ** " ។

## IV. សិក្ខាសាលា ស្តីពី ការផ្សព្វផ្សាយស្តង់ដារបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា

ការរៀបចំសិក្ខាសាលា ស្តីពី "**ការផ្សព្វផ្សាយស្តង់ដារបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា**" បានប្រព្រឹត្តទៅនាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** និងវត្តមានលោកជំទាវ ឯកឧត្តម ថ្នាក់ដឹកនាំក្រសួង ប្រធាន អនុប្រធាននាយកដ្ឋាន ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីទទួលបន្ទុកការងារបណ្ណាល័យមន្ទីរអប់រំ យុវជន និងកីឡា ២៥រាជធានី ខេត្ត អង្គការដៃគូ គ្រូឧទ្ទេសនិងអ្នកសម្របសម្រួល សរុប១៩៥នាក់/ស្រី៤៥នាក់។

សិក្ខាសាលានេះ មានគោលបំណងសំខាន់ គឺគាំទ្រដល់វត្ថុបំណងរបស់ទិវាជាតិអំណាន ពង្រឹងបន្ថែមលើការងារអំណាននៅតាមភូមិសិក្សា ដោយជំរុញ និងអភិវឌ្ឍបណ្ណាល័យនៅតាមសាលារៀនឱ្យមានដំណើរការល្អ។

### ក.របាយការណ៍វឌ្ឍនភាពស្តង់ដារបណ្ណាល័យ

លោក **ស៊ុន ម៉ុណ្ណារ៉ា ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា** បានបង្ហាញពីវឌ្ឍនភាពនៃស្តង់ដារបណ្ណាល័យ មាន ខ្លឹមសារដូចខាងក្រោម ៖

1) **សារតាបណ្ណាល័យ សម្តេច អគ្គមហាសេនាបតី តេជោហ៊ុន សែន និងលោកជំទាវ**
   - ២០០៧-២០០៨ ការសាងសង់ ជាអំណោយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ និងលោកជំទាវ**
   - ថ្ងៃទី១២ ឧសភា ២០០៨ សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
   - ថ្ងៃទី០៩ កញ្ញា ២០០៨ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាទទួលបន្ទុកគ្រប់គ្រង



- ថ្ងៃទី០៩ មិថុនា ២០០៩ ទទួលបន្ទុកអភិវឌ្ឍបណ្ណាល័យ

2) ចក្ខុវិស័យ និងបេសកកម្ម

- ផ្តល់សេវាកម្មដល់សាធាណៈជនទូទៅ ដើម្បីសិក្សាស្រាវជ្រាវ និងជំរុញទម្លាប់អាន
- កែលម្អគុណភាពអប់រំតាម ការអេភិវឌ្ឍបណ្ណាល័យបណ្តាញ
- ផ្តល់នូវព័ត៌មានសម្បូរណ៌បែប ស្របតាមគោលការណ៍អប់រំ សេវាកម្មប្រកបដោយគុណភាព
- ពង្រឹង និងអភិវឌ្ឍបណ្ណាល័យ តាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការ និងវិទ្យាស្ថានគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត
- បង្កើត និងអភិវឌ្ឍបណ្ណាល័យឈានមុខតាមបណ្តារាជធានី ខេត្ត។

3) តួនាទី និងភារកិច្ច

- ផ្គត់ផ្គង់សម្ភារៈ បរិក្ខារ បង្កើនឯកសារឱ្យកាន់តែសម្បូរណ៌បែបឆ្លើយតបតាមតម្រូវការអ្នកអាន
- ធ្វើបច្ចុប្បន្នភាពសេវាកម្ម និងកម្មវិធីកុំព្យូទ័របណ្ណាល័យ ដើម្បីសម្រួលពេលវេលាអ្នកអាន
- រៀបចំចងក្រងឯកសារទិវាជាតិអំណាន និងបង្កើតគេហទំព័រ ស្តីពី ទិវាជាតិអំណាន
- អភិវឌ្ឍឯកសារស្តង់ដារ និងឯកសារណែនាំបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា
- បំប៉នសមត្ថភាពគ្រូឧទ្ទេស គណៈគ្រប់គ្រងសាលា និងបណ្ណារក្សពីការងារបណ្ណាល័យ
- តាមដានពង្រឹងការងារបណ្ណាល័យ និងចងក្រងព័ត៌មានស្ថិតិបណ្ណាល័យទូទាំង២៥ រាជធានី ខេត្ត។

4) លទ្ធផលសម្រេចបាន

- ទទួលអ្នកអានជាមធ្យមបាន ១២០នាក់ក្នុងមួយថ្ងៃ
- មានសៀវភៅ និងឯកសារសរុប ២៥.៣១៨ ក្បាល ស្មើនឹង១០.០៤៨ ចំណងជើង
- បានអភិវឌ្ឍឯកសារស្តង់ដារ និងឯកសារណែនាំការងារបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា ដោយបោះពុម្ព និងផ្សព្វផ្សាយបានជូនទូទាំង ២៥រាជធានី ខេត្ត
- បង្កើត និងអភិវឌ្ឍបណ្ណាល័យបង្អែកបានចំនួន៩សាលា ស្ថិតក្នុង៩រាជធានី ខេត្ត
- បានបំប៉នការងារបណ្ណាល័យដល់គណៈគ្រប់គ្រង និងបណ្ណារក្សសាលារៀនចំណេះទូទៅ
- បានចុះតាមដាន និងពង្រឹងបណ្ណាល័យសាលារៀនចំណេះទូទៅ
- បានផ្គត់ផ្គង់គ្រឿងសង្ហារឹមដល់បណ្ណាល័យសាលាបឋមសិក្សា និងមធ្យមសិក្សា
- ប្រមូល និងចងក្រងព័ត៌មានស្ថិតិបណ្ណាល័យទូទាំង២៥ រាជធានី ខេត្ត ក្នុងឆ្នាំ២០២០ រួមមាន៖
  . សាលាបឋមសិក្សា ៧២១៩ មានបណ្ណាល័យចំនួន ៤១៣៣ សាលា
  . សាលាមធ្យមសិក្សាបឋមភូមិ ១២៥៩ មានបណ្ណាល័យចំនួន ៧៨៨ សាលា
  . សាលាមធ្យមសិក្សាទុតិយភូមិ ៥៣៤ មានបណ្ណាល័យចំនួន ៤៩៧ សាលា
- សហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ បានបង្កើតបណ្ណាល័យសាលារៀន បំពាក់ធនធាន គ្រឿងសង្ហារឹម សម្ភារបរិក្ខា និងឯកសារបានចំនួន ៤១សាលា ក្នុង១៣ រាជធានី ខេត្ត។

**5) ទិសដៅបន្ត**

- បង្កើនសមត្ថភាពមន្ត្រីទាំងផ្នែកបច្ចេកទេស និងភាសាបរទេស
- បង្កើនការផលិតសម្ភារបណ្ណាល័យ  រិះរកឯកសារឱ្យកាន់តែសម្បូរណ៍បែប និងកែលម្អសេវាកម្មបណ្ណាល័យដើម្បីឆ្លើយតបតម្រូវការអ្នកអាន និងអ្នកស្រាវជ្រាវ
- បង្កើនការផ្សព្វផ្សាយឯកសារស្តង់ដារ តួនាទី និងសារៈសំខាន់របស់បណ្ណាល័យឱ្យបានទូលំទូលាយ
- បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍក្នុងការពង្រីក និងអភិវឌ្ឍបណ្ណាល័យសាលារៀន
- បន្តរៀបចំការងារទិវាជាតិអំណាន ១១ មីនា  និងទិវាគ្រូបង្រៀន ៥ តុលា
- បំប៉នការងារបច្ចេកទេសបណ្ណាល័យ ដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ទាំងផ្នែកបឋម និងមធ្យមសិក្សា
- ប្រជុំឆ្លងយោបល់ឯកសារស្តង់ដារបណ្ណាល័យមធ្យមសិក្សា
- បង្កើតបណ្ណាល័យបង្អែកបន្ថែម និងផ្សព្វផ្សាយ
- ផ្គត់ផ្គង់សម្ភារៈ និងធនធានឯកសារដល់បណ្ណាល័យបណ្តាញ។

**ខ.ប្រសាសន៍សំណេះសំណាលរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា**




ប្រសាសន៍របស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋលេខាធិការ** បានលើកឡើង៣ចំណុចសំខាន់ៗ រួមមាន៖

១) ការផ្សព្វផ្សាយស្តង់ដារបណ្ណាល័យបឋមសិក្សានិងមធ្យមសិក្សា ដល់ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូអភិវឌ្ឍ ត្រូវធ្វើឱ្យបានទូលំទូលាយ

២) ពិគ្រោះយោបល់រកបញ្ហាប្រឈម ឆ្លុះបញ្ចាំងពីសូចនាករស្តង់ដារនីមួយៗ ដោយធ្វើការផ្ទៀតផ្ទាត់ជាមួយនឹងការអភិវឌ្ឍបណ្ណាល័យសាលារៀន

៣) យកចំណុចល្អដែលទទួលបានពីការបញ្ចេញមតិយោបល់ក្នុងអង្គសិក្ខាសាលាដើម្បីជាធាតុចូល ក្នុងការកែលម្អឯកសារស្តង់ដាបណ្ណាល័យ ឱ្យកាន់តែល្អបន្ថែមទៀត។

នាក្នុងឱកាសនោះដែរ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋលេខាធិការ** មានប្រសាសន៍បញ្ជាក់បន្ថែមថា ឯកសារស្តង់ដារបណ្ណាល័យនេះជាជំនួយក្នុងការជម្រុញ  និងការអភិវឌ្ឍបណ្ណាល័យសាលារៀនឱ្យកាន់តែល្អប្រសើរ  ទាំងការបង្កើតបណ្ណាល័យ ការបំពាក់សម្ភារៈបរិក្ខា ឯកសារ និងការគ្រប់គ្រងបណ្ណាល័យ ឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស ដោយគ្រប់បណ្ណាល័យនៃសាលារៀនទាំងអស់ ត្រូវបំពាក់ម៉ាស៊ីនត្រជាក់ រួមជាមួយបរិក្ខាផ្សេងៗ ធ្វើយ៉ាងណាទាក់ទាញទឹកចិត្តអ្នកអាន ឱ្យចូលរួមអានជាប្រចាំ ពីព្រោះថាឯកសារនៅក្នុងបណ្ណាល័យវានឹងស្លាប់បើគ្មានអ្នកអាន។

**គ.បទបង្ហាញរបស់លោក ម៉ុត រ៉ាស៊ី ប្រធានស្តីទីការិយាល័យបណ្ណាល័យនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

បទបង្ហាញមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

1. អត្ថន័យបណ្ណាល័យល្អ  ស្ថានភាព និងបញ្ហាប្រឈម របស់បណ្ណាល័យក្នុងពេលបច្ចុប្បន្ន
2. ការងារស្នូលសំខាន់ៗរបស់បណ្ណាល័យ

3. សមាសភាគ និងខ្លឹមសារស្តង់ដារបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា ដូចជា សមាសភាគទី១ ធនធានមនុស្ស និងការពិនិត្យតាមដាន សមាសភាគទី២ ស្ថានភាពបណ្ណាល័យ ធនធានសម្ភារៈ និងឯកសារ សមាសភាគទី៣ ការងារបច្ចេកទេស និងរដ្ឋបាល។

**ឃ.បទបង្ហាញរបស់លោក ហោ សុខៈ តំណាងអង្គការរូមធ្យូម៉ែកម្ពុជា**

ខ្លឹមសារបទបង្ហាញ ស្តីពី បទពិសោធន៍ដំណើរការងារបណ្ណាល័យនៅសាលាបឋមសិក្សា រួមមានៈ

- ការផលិតសៀវភៅឱ្យសមស្របតាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកអាន
- កន្លែងសម្រាប់អ្នកអានរៀបចំឱ្យបានសមស្រប
- ការចូលរួមអភិវឌ្ឍបណ្ណាល័យតាមបណ្តារាជធានី ខេត្ត ចំនួន៧ និង១៦ប្រទេសផ្សេងទៀត
- ផែនការ និងសកម្មភាពលើការងារបណ្ណាល័យ។

## V. សេចក្តីសន្និដ្ឋាន

ការរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៥ ថ្ងៃ១១ មីនា ឆ្នាំ២០២០ បានប្រព្រឹត្តទៅដោយរលូនតាមកម្មវិធីដែលបានគ្រោងទុក និងលទ្ធផលជាទីមោទនយ៉ាងក្រៃលែងបំផុត ដោយកម្មវិធីនីមួយៗនៃដំណើរការទិវាជាតិអំណានមានភាពប្រសើរ និងរីកចំរើនជាងឆ្នាំកន្លងៗមក ដូចជា ១)បរិមាណស្តង់តាំងពិព័រណ៍សៀវភៅមានការកើនឡើង ២)អ្នកនិពន្ធមានការចូលរួមកើនឡើង ៣)ពង្រីកបន្ថែមកម្មវិធីសិក្ខាសាលា និងយុទ្ធនាការ ។ ទន្ទឹមនឹងគុណសម្បត្តនេះ ក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួច ដូចជាសមាជិកគណៈកម្មការរៀបចំមួយចំនួនជាប់បេសកកម្ម ចំណុចខ្វះខាតនេះ និងផ្សេងៗទៀតបានក្លាយជាបទពិសោធន៍សម្រាប់រៀបចំទិវាជាតិអំណានលើកទី៦ឆ្នាំ២០២១និងឆ្នាំបន្តបន្ទាប់ទៀត។

ថ្ងៃអង្គារ ៨កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២០
**អ្នកធ្វើរបាយការណ៍**

ឈាង តារ៉ុ

បានឃើញ និងសូមគោរពជូន
**"ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី"**
ក្រសួងអប់រំ យុវជន និងកីឡា "មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់"
ថ្ងៃអង្គារ ៨កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០
**ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

ស៊ុន_ប៊ុណ្ណា

បានឃើញ និងឯកភាព
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

## VI-ឧបសម្ព័ន្ធ

**រូបភាពទី១** ផែនទីស្តង់តាំងពិព័រណ៍សៀវភៅ



**រូបភាពទី ២** បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំង " **អានអត្ថបទ** "

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | អង្គភាព | រាជធានី ខេត្ត |
|---|---|---|---|---|---|
| 1 | ដុះ ស្រីជា | ស | **3/17/2009** | បឋម.កំពង់ស្លែង | តាកែវ |
| 2 | ចាប ពិសី | ស | 10/26/2008 | បឋម.ដើមស្វាយ | កំពត |
| 3 | ឈួ រាជនី | ស | 12/16/2008 | បឋម.ហ៊ុន សែនកែវកេរសាំង | កែប |
| 4 | គង់ បូតា | ស | 9/21/2008 | បឋម.ប៉ោយអង្គរ | បជ័យ |
| 5 | ឈាង ភក្តី | ស | 8/21/2009 | បឋម.ព្រះក្រសាំង | កំពង់ធំ |
| 6 | សាន សូលីកា | ស | 12/18/2008 | បឋម.ព្រែកគយ | កណ្តាល |
| 7 | ខា មិនឈី | ស | 1/8/2008 | បឋម.ហូព | បាត់ដំបង |
| 8 | ប្រាក់ ឡាយសុខហេង | ស | 10/17/2008 | បឋម.ប៉ាហ៊ី | ប៉ៃលិន |
| 9 | ជឿន ស្រីកា | ស | 2/18/2008 | បឋម.ចុងព្រែក | ស្វាយរៀង |
| 10 | ណារ៉ុង សួស្តី | ស | 1/12/2009 | បឋម.អេង អូ អេស | សៀមរាប |
| 11 | ឡុង សុជាវដ្តី | ស | 5/5/2009 | បឋម.ព្រុំ សុនក្តីកណ្តាល | ព្រៃវែង |
| 12 | ម៉ម សុខរីហ្សា | ស | 11/13/2007 | បឋម.ហ៊ុនសែន សែនមនោរម្យ | មណ្ឌលគិរី |
| 13 | រឿន វណ្ណដានិច្ច | ស | 2/24/2009 | បឋម.ទួលថ្ម | កំពង់ចាម |
| 14 | សៀន សុខហេង | ស | 2/18/2009 | បឋម.ជំទាវសុខ | កំពង់ឆ្នាំង |
| 15 | ផែន សុជា | ស | 11/13/2008 | បមឋ.អូរគគីរ | ឧត្តរមានជ័យ |
| 16 | ហួន ហុងមុី | ស | 2/16/2008 | បឋម.ប្រាំបីមុម | កំពង់ស្ពឺ |
| 17 | វ៉េន ប៊ុនជឿន | ប | 8/10/2008 | បឋម.ធីយូអឹម អន្តជាតិ | កោះកុង |
| 18 | ឧត្តម វរៈទេវី | ស | 1/24/2009 | បឋម.ព្រះនរោត្តម | ភ.ព |
| 19 | សេង ឡាដា | ស | 9/16/2009 | បឋម.ស៊ីហ៊ូហ៊ុយវត្តជីដុះ | ក្រចេះ |
| 20 | នាង អេលីណា | ស | 6/21/2009 | វិ.ឯកជនគ្រូយើង | រតនគីរី |
| 21 | អេង ស្រីយា | ស | 2/9/2009 | បឋម.បន្ទាយមៀន | ត្បូងឃ្មុំ |
| 22 | ពន្លឺ សុគន្ធរីហ្សា | ស | 6/27/2008 | បឋម.ត្បែងមានជ័យ | ព្រះវិហារ |
| 23 | ចាន់ សំណាង | ប | 1/1/2009 | បឋម.ទំនប់រលកថ្មី | ព្រះសីហនុ |
| 24 | វ៉ុង សៀងឌី | ស | 2/15/2007 | បឋម.ទួលគ្រួស | ពោធិ៍សាត់ |
| 25 | កត្តា លក្ខណា | ស | 9/15/2007 | បឋម.សេសាន | ស្ទឹងត្រែង |

## រូបភាពទី៣ បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំង " **ស្មូតកំណាព្យ** "

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំ កំណើត | អង្គភាព | រាជធានី ខេត្ត | ចំណងជើង | កំណាព្យបទ | សូត្រតែបប |
|---|---|---|---|---|---|---|---|---|
| 1 | ហ៊ុន ធីតា | ស | 9/22/2005 | វិ.សុខ អានថ្នល់បំបែក | តាកែវ | គ្រាប់ពូជអំណាន | ពាក្យ៧ | ភុជង្គលីលា |
| 2 | សាង ផល្លីន | ស | 2/28/2003 | វិ.កន្សោមអក | កំពត | ជីវិតខ្មែរក្នុងរបបវាពិឃាដ | ពាក្យ៧ | ទំនួញ |
| 3 | ជ ចា | ស | 4/3/2005 | អនុវិ.ហ៊ុនសែនអង្គោល | កែប | គុណតម្លៃគ្រូ | កាកគតិ | ពុទ្ធបាទប្រាំឋាន |
| 4 | កែម សៀវម៉ី | ស | 5/3/2005 | អនុវិ.ម្កាក់ | ប.ជ | ការអានបណ្តុះបញ្ញាការស្រាវជ្រាវ និងនវានុវត្តន៍ | ពាក្យ៧ | រាស់ |
| 5 | ខំ យុននី | ស | 10/4/2005 | វិ.ហ៊ុន សេន សណ្តាន់ | កំពង់ធំ | ការពិតក្នុងរបបប្រជាធិបតេយ្យ | កាកគតិ | ពុទ្ធបាទប្រាំឋាន |
| 6 | មុំ ចរិយា | ស | 1/21/2006 | វិ.ហ៊ុន សែន ស្អាង | កណ្តាល | សហប្បតីព្រហ្ម | ព្រហ្មគិត | ព្រហ្មជើងត្រៃ |
| 7 | ឈិត វឌ្ឍា | ប | 9/7/2004 | វិ.ហ៊ុនសែនត្រែង | បាត់ដំបង | រំលឹកគុណគ្រូ | កាកគតិ | ពុទ្ធបាទប្រាំឋាន |
| 8 | លឿ ស្រីណាវ | ស | 3/1/2006 | អនុវិ.បយ៉ាខា | ប៉ៃលិន | គុណគ្រូ | ពាក្យ៧ | មេទ្រីបា |
| 9 | ប្រាក់ សំណាង | ស | 10/25/2005 | វិ.ហ ស កំពង់ពោធិ៍ | ស្វាយរៀង | គុណគ្រូបង្រៀន | កាកគតិ | ក្អែកលោតទី១ |
| 10 | លន់ សុវណ្ណលុច | ស | 4/2/2000 | វិ.អប់រំពិសេស | សៀមរាប | គោថ្ម | ពាក្យ៨ | ពណ៌នា |
| 11 | ភារម្យ ស្រីវឌ្ឍ | ស | 9/13/2007 | អនុវិ.ភ្លៀត | ព្រៃវែង | អំណាចនៃអំណាន | ពាក្យ៧ | ខមាទោស |
| 12 | ជួន តុលា | ស | 11/4/2002 | វិ.ហ៊ុន សេន មណ្ឌលគិរី | មណ្ឌលគិរី | សារៈសំខាន់នៃអំណាន | ពាក្យ៧ | ខមាទោស |
| 13 | លី ធានឡាយ | ប | 4/7/2005 | វិ.សម្តេចតេជោ ហស ស្ទឹងត្រង់ | កំពង់ចាម | គុណតម្លៃនៃអំណាន | ពាក្យ៧ | ទំនួញព្រះនាងពិម្ពា |
| 14 | ហ៊ល លំអង | ស | 5/23/2005 | វិ.ជាស៊ីមកំពង់ត្រឡាច | កំពង់ឆ្នាំង | ការប្រដៅជាស់តឿន | ពាក្យ៧ | ទំនួញ |
| 15 | វន់ ស្រីម៉ៅ | ស | 4/25/2004 | អនុវិ.អូរស្វាយ | ឧត្តរមានជ័យ | ក្តីស្រលាញ់នៃមាតា | ពាក្យ៧ | ទំនួញនាងមេទ្រី |
| 16 | ជឿន បញ្ញា | ប | 9/19/2004 | វិ.ឌីប៊ុក | កំពង់ស្ពឺ | ពេលម៉ែប្រសូត្រ | ពាក្យ៧ | ទំនួញ |
| 17 | ផាន់ សុផាន | ស | 3/27/2007 | អនុវិ.តាទៃលើ | កោះកុង | ឧត្តមភាពជាតិ | ពាក្យ៧ | រាស់ |
| 18 | ផាន់ ស្រីណុច | ស | 6/7/2006 | វិ.បាក់ទូក | រាជធានីភ្នំពេញ | វប្បធម៌អប់រំ | ពាក្យ៧ | មេទ្រីបា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 19 | ផល ជូលី | ស | 9/21/2007 | អនុវិ.ជីផុះ | ក្រចេះ | ប្រាសាទសិលាខ្មែរ | ពាក្យ៧ | ទំនួញ |
| 20 | ធឿន សុខលីន | ស | 9/12/2005 | អនុវិ.អូរយ៉ាដាវ | រតនគីរី | តម្លៃជីវិត | កាកកតិ | ក្អែកលោតទី១ |
| 21 | អង កញ្ញា | ស | 1/15/2005 | អនុវិ.ពពេល | ត្បូងឃ្មុំ | បណ្តាំឪពុក | កាកគតិ | ពុទ្ធបាទប្រាំឋាន |
| 22 | ឡូញ លៀញ | ស | 1/7/2004 | អនុវិ.ភ្នំត្បែងពីរ | ព្រះវិហារ | ប្រគេនពរព្រះគ្រូ | កាកគតិ | ពុទ្ធបាទប្រាំឋាន |
| 23 | គុណ គា | ប | 2/3/2008 | អនុវិ.តេជោរសែនកម្មករ | ព្រះសីហនុ | ប្រាសាទសិលាខ្មែរ | ពាក្យ៧ | បែបរាស់ |
| 24 | ឆែម លាងហេង | ស | 12/19/2005 | វិ.នទីសេដ្ឋ | ពោធិ៍សាត់ | ការអានបណ្ដុះបញ្ញា | ពាក្យ៧ | ទំនួញ |
| 25 | ថាន ស៊ីធាន | ប | 2/2/2002 | វិ.ប៊ុនរ៉ានី ហ.សអូរ ពងមាន់ | ស្ទឹងត្រែង | ទំនួញសុវណ្ណសាម | ពាក្យ៧ | ទំនួញ |

**រូបភាពទី ៤** បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំង " **តែងនិពន្ធ** "

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | អង្គភាព | រាជធានី ខេត្ត |
|---|---|---|---|---|---|
| 1 | ហេង មៀនមៀន | ស | 4/27/2002 | វិ.សម្តេចឪ | តាកែវ |
| 2 | ងួន សុធារីកា | ស | 11/8/2002 | វិ.ជាស៊ីម អង្គរជ័យ | កំពត |
| 3 | សាត គឹមកង | ស | ១០/០៣/០២ | វិ.ហ៊ុនសែនចំការដូង | កែប |
| 4 | សាំង វ៉ាន់ណៃ | ប | 12/17/2003 | វិ.អូរអំបិល | បន្ទាយមានជ័យ |
| 5 | គី ពុទ្ធី | ប | 1/3/1999 | វិ.ហ៊ុន សែន បល្ល័ង្គ | កំពង់ធំ |
| 6 | ផន ស្រីល័ក្ខ | ស | 6/16/2002 | វិ.សម្តេចតេជោ ហ៊ុន សែន ក្រាំងយ៉ូវ | កណ្តាល |
| 7 | សឿម សិរីម៉ារឌី | ស | 5/7/2005 | វិ.កំរៀង | បាត់ដំបង |
| 8 | អ៊ុង សារឿន | ប | 1/4/2002 | វិ ហ.ស ក្រុងទេពនិមិ្មត | ប៉ៃលិន |
| 9 | ឱននា ឧត្តម | ប | 2/6/2004 | វិ.ប៊ុនរ៉ានី ហស ចន្ទ្រា | ស្វាយរៀង |
| 10 | ប៊ុន រស្មី | ប | 4/14/2000 | វិ.ត្រពាំងប្រិយ៍ | សៀមរាប |
| 11 | កាន ស្រីនីត | ស | 4/13/2001 | វិ.មេសាង | ព្រៃវែង |
| 12 | វីរៈ សុភ័ណ្ឌដារី | ស | 9/22/2000 | វិ.ហ៊ុន សែន មណ្ឌលគិរី | មណ្ឌលគិរី |
| 13 | ហុី ណារ៉ូ | ប | 10/7/2002 | វិ.សម្តេចតេជោ ហស ស្ទឹងត្រង់ | កំពង់ចាម |
| 14 | លី ប៊ុនរិទ្ធ | ប | 8/9/2002 | វិ.ហស.បរិបូណ៌ | កំពង់ឆ្នាំង |
| 15 | អោត រ៉េត | ប | 10/10/2001 | វិ.តេជោ ហស ត្រពាំងតាវ | ឧត្តរមានជ័យ |
| 16 | សែម បាន | ប | 2/8/2002 | វិ.ហ៊ុនសេនភ្នំស្រួច | កំពង់ស្ពឺ |
| 17 | ហៀន ទូត | ស | 12/17/2001 | វិ.ស្រែអំបិល | កោះកុង |
| 18 | កុសល ស្រីមាស | ស | 6/21/2004 | វិ.ព្រែកលាប | រាជធានីភ្នំពេញ |
| 19 | ពូន ហ៊ុយជីង | ស | 3/14/2004 | | ក្រចេះ |
| 20 | ផៃ ណារី | ស | 12/21/2001 | វិ.សម្តេចឪ សម្តេចម៉ែ | រតនគីរី |
| 21 | ជៀប សុខនាទ | ស | 1/2/2000 | វិ.សតហាសសួង | ត្បូងឃ្មុំ |
| 22 | ហ៊ូ សោភារម្យ | ស | 5/8/2003 | វិ.ច.ប.ជាស៊ីមត្បែងមានជ័យ | ព្រះវិហារ |
| 23 | ជូន សាមុីឌី | ប | 12/28/2002 | វិ.ក្រុងព្រះសីហនុ | ព្រះសីហនុ |
| 24 | ប៉ាន់ ស្រីនាង | ស | 9/30/2004 | វិ.ពោធិ៍សាត់ | ពោធិ៍សាត់ |
| 25 | កោយ ជិកា | ស | ២២/១១/០៣ | វិ.ទួលវិជ្ជា | ស្ទឹងត្រែង |

**រូបភាពទី ៥** បញ្ជីឈ្មោះបេក្ខជនជ័យលាភីប្រឡងប្រណាំង " **អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ** "

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

អគ្គនាយកដ្ឋានអប់រំ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## បេក្ខជនជ័យលាភី

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

## អបអរសាទរទិវាជាតិអំណាន ១១ មីនា ២០២០

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃ-ខែ-ឆ្នាំកំណើត | ថ្នាក់ទី | មកពីសាលា | ខេត្ត-រាជធានី | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|
| **ក. ជ័យលាភីផ្នែក អាន** | | | | | | | |
| ១ | **នាង អេលីណា** | ស្រី | ២១-មិថុនា-២០០៩ | ៦ | វិទ្យាល័យឯកជនគ្រូយើង | រតនគិរី | ១ |
| ២ | **ឡុង សុជាថវី** | ស្រី | ០៥-ឧសភា-២០០៩ | ៦ | សាលាបឋមសិក្សាព្រុំសុនក្តីកណ្តាល | ព្រៃវែង | ២ |
| ៣ | **ដុស ស្រីធា** | ស្រី | ១៧-មីនា-២០០៩ | ៦ | សាលាបឋមសិក្សាកំពង់ស្លែង | តាកែវ | ៣ |
| **ខ. ជ័យលាភីផ្នែក ស្មូតកំណាព្យ** | | | | | | | |
| ១ | **គុណា តា** | ប្រុស | ០៣-កុម្ភៈ-២០០៨ | ៧ | អនុវិទ្យាល័យ.តេជោសែនកម្មករ | ព្រះសីហនុ | ១ |
| ២ | **ហ៊ិន ធីតា** | ស្រី | ២២-កញ្ញា-២០០៥ | ៩ | វិទ្យាល័យសុខអានថ្នល់បំបែក | តាកែវ | ២ |
| ៣ | **ខំ យុននី** | ស្រី | ០៤-តុលា-២០០៥ | ៩ | វិទ្យាល័យហ៊ុនសែនសណ្តាន់ | កំពង់ធំ | ៣ |
| **គ. ជ័យលាភីផ្នែក តែងនិពន្ធ** | | | | | | | |
| ១ | **ហោង មៀនមៀន** | ស្រី | ២៧-មេសា-២០០២ | ១២ | វិទ្យាល័យសម្តេចឪ | តាកែវ | ១ |
| ២ | **ខួន សុធារីកា** | ស្រី | ០៨-វិច្ឆិកា-២០០២ | ១១ | វិទ្យាល័យសម្តេចជាស៊ីមអង្គរជ័យ | កំពត | ២ |
| ៣ | **ភាន ស្រីនីត** | ស្រី | ១៣-មេសា-២០០២ | ១១ | វិទ្យាល័យមេសាង | ព្រៃវែង | ៣ |

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០

ជ. **គណៈកម្មការវាយតម្លៃដាក់ពិន្ទុ**

**បានឃើញ និងឯកភាព**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

រូបភាពទី ៦ បញ្ជីឈ្មោះបេក្ខជនជ័យប្រឡងប្រណាំង " **តាក់តែងសិក្សាកថា** "

| លរ. | គោត្តនាមនាម- | | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខរបរ | អង្គភាព | ខេត្ត |
|---|---|---|---|---|---|---|---|
| **ប្រធានបទទី១ តួនាទីអក្សរសិល្ប៍ក្នុងសង្គម** | | | | | | | |
| ១ | គាំ | យ៉េង | ប្រុស | ១៩១៩៨៤-កក្កដា- | គ្រូបង្រៀន | វិ.ស្វាយចេក | ប.ជ័យ |
| ២ | ណៃម | ណុំ | ប្រុស | ០៧១៩៨៤-មិថុនា- | គ្រូបង្រៀន | អនុ.វិ.អូរស្វាយ | ស្ទឹងត្រែង |
| ៣ | ទឹម | សុខហួយ | ប្រុស | ០៩១៩៨៩-មីនា- | គ្រូបង្រៀន | វិ.អង្គសង្កែ | តាកែវ |
| ៤ | ទេព | ផល្លីណា | ប្រុស | ០២កុម្ភៈ១៩៨២ | គ្រូបង្រៀន | វិ.ដំដែក | សៀមរាប |
| ៥ | ប៊ុន | តុលី | ប្រុស | ០៧១៩៨៩-កញ្ញា- | គរុសិស្ស | សាលាគរុ.វិក្រឹ. | កំពង់ចាម |
| ៦ | ផល្លា | សុម៉ាលីណា | ស្រី | ២២១៩៩០-មិថុនា- | គ្រូឧទ្ទេស | សាលាគរុ.វិក្រឹ. | កំពង់ចាម |
| ៧ | ផល្លា | សុវណ្ណឬទ្ធិ | ប្រុស | ០៨១៩៨៤-វិច្ឆិកា- | បុគ្គលិក | សាកលវិ.ពុទ្ធិសាស្ត្រ | ភ្នំពេញ |
| ៨ | ផៃ | សេងហាក់ | ប្រុស | ០៧១៩៨៥-កញ្ញា- | គ្រូបង្រៀន | វិ.ស ខេង កន្ទឺ២ | បាត់ដំបង |
| ៩ | ព្រឹម | ប្រាក់រស្មី | ប្រុស | ០១១៩៧៨-ឧសភា- | គ្រូបង្រៀន | វិមិត្តភាពកម្ពុជាជប៉ុនកំពតក្រុង. | កំពត |
| ១០ | ព្រំ | ចាន់ថន | ប្រុស | ១៦១៩៨២-កញ្ញា- | គ្រូបង្រៀន | វិ.ទ្រៀល | កំពង់ធំ |
| ១១ | យ៉ុង | យ៉ុន | ប្រុស | ០៧១៩៨៨-ធ្នូ- | គ្រូបង្រៀន | វិ.ហ៊ុនសែនស្អាង | កណ្ដាល |
| ១២ | យ៉ែម | មករា | ប្រុស | ០៨១៩៨៩-មករា- | គ្រូបង្រៀន | វិ.អង្គរកា | តាកែវ |
| ១៣ | រស់ | វាសនា | ប្រុស | ១៤១៩៨៧-វិច្ឆិកា- | គ្រូបង្រៀន | វិ.ហ៊ុនសែនបាគង | សៀមរាប |
| ១៤ | សង | ហេង | ប្រុស | ០៦១៩៦៧-វិច្ឆិកា- | គ្រូបង្រៀន | អនុវិ.ឧទុម្ពរ | កំពង់ធំ |
| ១៥ | សារ៉ែន | វិរៈ | ប្រុស | ១០១៩៨៤-មិថុនា- | គ្រូបង្រៀន | សាលាបឋម.ភូមិថ្មី | កណ្ដាល |
| **ប្រធានបទទី២ តួនាទីទស្សនាវដ្ដីកម្ពុសុរិយាក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរ** | | | | | | | |
| ១៦ | ជា | សារី | ប្រុស | ០៥១៩៧៩-កុម្ភៈ- | គ្រូបង្រៀន | វិ.១០មករា១៩៧៩ | សៀមរាប |
| ១៧ | ឡុង | ធរង្ស | ប្រុស | ០៧១៩៩២-តុលា- | គ្រូបង្រៀន | វិ.សម្ដេចអគ្គហ៊ុនសែនសំរោង. | ភ្នំពេញ |
| **ប្រធានបទទី៣ ការតែងនិពន្ធក្នុងយុគសម័យទំនើប ( ឌីជីថល )** | | | | | | | |
| ១៨ | មិន | ម៉ៅសំណាង | ប្រុស | ០៥១៩៩៣-ឧសភា- | សារព័ត៌មាន | ស្ថានីយទូរទស្សន៍ PNN | ភ្នំពេញ |
| ១៩ | អ៊ឹម | សានី | ប្រុស | ១៧១៩៨៥-មេសា- | បុគ្គលិក | មន្ទីរ អយក. | ឧ.ជ័យ |

**រូបភាពទី ៧** បញ្ជីឈ្មោះបេក្ខជនជ័

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**ចំណាត់ថ្នាក់ជម្រើសបេក្ខជនចុងក្រោយ**
**ក្នុងការប្រឡងប្រណាំងស្នាដៃសិក្សាកថាទាំងបីប្រធានបទ**
**អបអរសាទរទិវាជាតិអំណាន ១១ មីនា ២០២០**

| ល.រ | គោត្តនាម-នាម | | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខរបរ | អង្គភាព | ខេត្ត | ពិន្ទុ | ចំណាត់ថ្នាក់ | |
|---|---|---|---|---|---|---|---|---|---|---|
| ក. ប្រធានបទទី១ តួនាទីអក្សរសិល្ប៍ក្នុងសង្គម | | | | | | | | | | |
| ១ | យ៉ែម | មករា | ប្រុស | ០៨-មករា-១៩៨៩ | គ្រូបង្រៀន | វិទ្យាល័យអង្គរកា | តាកែវ | 8.50 | ១ | |
| ខ. ប្រធានបទទី២ តួនាទីទស្សនាវដ្ដីកម្ពុជសុរិយាក្នុងការលើកកម្ពស់អក្សរសិល្បខ្មែរ | | | | | | | | | | |
| ១ | ឡុង | ធវង្ស | ប្រុស | ០៧-តុលា-១៩៩២ | គ្រូបង្រៀន | វិ.សម្ដេចអគ្គ.ហ៊ុនសែនសំរោង | ភ្នំពេញ | 9.00 | ១ | |
| គ. ប្រធានបទទី៣ ការតែងនិពន្ធក្នុងយុគសម័យទំនើប (ឌីជីថល) | | | | | | | | | | |
| ១ | មិន | ម៉ៅសំណាង | ប្រុស | ០៥-ឧសភា-១៩៩៣ | អ្នកសារព័ត៌មាន | ស្ថានីយទូរទស្សន៍ PNN | ភ្នំពេញ | 8.75 | ១ | |

- ប្រធានបទទី១ បេក្ខជនសរុបចំនួន ០៣នាក់/ស្រីចំនួន ០ នាក់
- ប្រធានបទទី២ បេក្ខជនសរុបចំនួន ០២នាក់/ស្រីចំនួន ០ នាក់
- ប្រធានបទទី៣ បេក្ខជនសរុបចំនួន ០២នាក់/ស្រីចំនួន ០ នាក់

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០
**អ្នករាយការណ៍**

**បានឃើញ និងឯកភាព**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**